ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




លេខ ៦ | ឆ្នាំ២០១៩

# បុព្វកថា

គិតចាប់ពីជំហានដំបូងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យើងទាំងអស់គ្នាបានឆ្លងកាត់នូវរឿងរ៉ាវជាច្រើន សប្បាយផង, បារម្ភផង, ជូរចត់ផង ប៉ុន្តែដោយហេតុតែស្មារតី និងឆន្ទៈដ៏មោះមុតឥតនឿយហត់ ជាមួយនឹងអភិក្រម "**រៀនផង ធ្វើផង**" និងមានការជំរុញគាំទ្រយ៉ាងខ្លាំងក្លាពី **អគ្គមហារដ្ឋបុរស** គឺ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើឱ្យអំរែកដ៏ធ្ងន់នេះ មានភាពធូរស្រាលបន្តិច-ម្តងៗ ហើយនៅទីបំផុត យើងសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើនគួរជាទីមោទនៈ ដែលបានរួមចំណែកសម្រេចនូវគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ហេតុនេះហើយ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងនៅតែបន្តជាអាទិភាពមួយនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមអភិក្រមជាខឿន បានបោះជំហានពីមួយដំណាក់កាលទៅមួយដំណាក់-កាល និងជាជំហានៗ ជាមួយនឹងភាពជោគជ័យជាបន្តបន្ទាប់ ដោយបច្ចុប្បន្ន យើងបានឈានមកដល់ដំណាក់កាលទី៣ ដែលកំពុងផ្តោតសំខាន់លើ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**"។ ជាមួយនឹងចក្ខុវិស័យច្បាស់លាស់ និងប្រាកដប្រជា, កម្ពុជាបាននិងកំពុងប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្តោតលើធាតុចូល និងមធ្យោបាយ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដារអន្តរជាតិ។ បន្ថែមពីនេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ ដែលទើបទទួលបានការអនុម័តក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីកាលពីខែមករា ឆ្នាំ២០១៨ ក៏បានដាក់ឱ្យអនុវត្តក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីខែមេសា ឆ្នាំ២០១៨ កន្លងទៅ។

ក្នុងបរិការណ៍សេដ្ឋកិច្ចកំពុងមានការរីកចម្រើន, កម្មវិធីកែទម្រង់ក៏បានចូលរួមជំរុញកំណើនសេដ្ឋកិច្ចឱ្យសម្រេចបានជាមធ្យមក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ប្រកបដោយសមធម៌, បរិយាប័ន្ន និងធន់នឹងវិបត្តិ ដែលរឹតតែធ្វើឱ្យកម្រិតជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង។ លើសពីនេះ, ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ, ចំណូលចរន្តថវិការដ្ឋបានកើនឡើងផង, ការអនុវត្តចំណាយកាន់តែខិតទៅជិតគោលដៅនៃច្បាប់ថវិកា ដែលបានជំរុញឱ្យមានអតិរេកសាច់ប្រាក់ និងកាត់បន្ថយឱនភាពសរុប ព្រមទាំងធានាមិនឱ្យមានបំណុលកកស្ទះដ៏រ៉ាំរ៉ៃ, និងបំណុលសាធារណៈ ក៏ត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ។ កត្តាទាំងអស់នេះ បានធានាថា ភាពទុកចិត្តនៃថវិកា កាន់តែប្រសើរឡើង ហើយជាពិសេសបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលក្នុងការដំឡើងបៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់-ថ្នាក់ ថែមទៀតផង។ ដោយឡែក គណនេយ្យភាពហិរញ្ញវត្ថុក៏ត្រូវបានធានាផងដែរ តាមរយៈការឆ្លុះបញ្ចាំងពីភាពបុរេសកម្មការងារជាពិសេសការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបែបព័ត៌មានវិទ្យា (ដែលហៅកាត់ថា FMIS), ការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួង-ស្ថាប័ន, ព្រមទាំងការរៀបចំ កែលម្អ និងការពង្រឹងច្បាប់និងបទបញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តថវិកា។ ជាការគួរឱ្យកត់សម្គាល់, ក្នុងពេលថ្មីៗនេះ, របាយការណ៍អង្កេតតម្លាភាពថវិកាអន្តរជាតិបានវាយតម្លៃថា តម្លាភាពថវិកានៅកម្ពុជា មានវឌ្ឍនភាពល្អប្រសើរក្នុងឆ្នាំ២០១៧ បើធៀបនឹងឆ្នាំ២០១៥ កន្លងទៅ។ រីឯការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ក្នុងដំណាក់កាលទី៣ នេះ, គ្រប់ក្រសួង-ស្ថាប័ន បាននិងកំពុងអនុវត្តពេញលេញនូវថវិកាកម្មវិធី ទន្ទឹមគ្នាជាមួយនឹងការកែសម្រួលរចនា-សម្ព័ន្ធគោលនយោបាយ, ផែនការយុទ្ធសាស្ត្រថវិកា, និងក្របខ័ណ្ឌគតិយុត្តនានា សម្រាប់ការអនុវត្តថវិកាកម្មវិធី។ លើសពីនេះទៀត, យន្តការអង្គភាពថវិកាដើម្បីជំរុញតម្លាភាព, គណនេយ្យភាព, ការផ្ទេរសិទ្ធអំណាច, ការទទួលខុសត្រូវ និងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ក៏ត្រូវបានរៀបចំ និងពង្រឹងជាបន្តបន្ទាប់។

ជាការពិត, ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាពិសេសក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ដោយជាមធ្យមស្ថិតក្នុងរង្វង់ ៧%។ កំណើននេះ ត្រូវបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ដោយស្ថាប័នអន្តរជាតិ ថាជាកំណើនដែលពុំធ្លាប់មានពីមុនមកក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់។ ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, ការកែលម្អរដ្ឋបាលសារពើពន្ធ និងការធ្វើទំនើបកម្មប្រព័ន្ធពន្ធដារ ដែលបង្កភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ, ការវិភាជថវិកាកាន់តែចំគោលដៅអាទិភាព និងមានប្រសិទ្ធភាពខ្ពស់ជាងមុន, ព្រមទាំងការអនុវត្តនូវថវិកាកម្មវិធី គឺជាកត្តាជំរុញដ៏សំខាន់ក្នុងការសម្រេចបាននូវសមិទ្ធផលខាងលើ។ ម្យ៉ាងវិញទៀត, កម្មវិធីកែទម្រង់នេះ បានបង្កើតឱកាសជំរុញឱ្យគ្រប់ក្រសួង

ស្ថាប័ន ពង្រឹងការផ្ដល់សេវាសាធារណៈ ឱ្យកាន់តែងាយស្រួល, តម្លាភាព, អាចជឿទុកចិត្តបាន,ឆាប់រហ័ស និងមានប្រសិទ្ធភាពសម្រាប់អ្នកប្រើប្រាស់សេវា ព្រមទាំងបានរួមចំណែកកសាងអភិបាលកិច្ចល្អនៅតាមស្ថាប័ននីមួយៗ ដែលជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជារួម ដោយសារការប្រតិបត្តិឥតរួញរាក្រោមការចង្អុលបង្ហាញរបស់ប្រមុខរាជរដ្ឋាភិបាល, ការបង្កើតបាននូវសមិទ្ធផលដ៏ធំធេងទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះក្នុងការកសាងនូវទំនុកចិត្តកាន់តែខ្លាំងឡើងក្នុងចំណោមមន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ និងសាធារណជនចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបានជោគជ័យដ៏ធំធេងក្នុងការប្រែក្លាយកម្ពុជាពីប្រទេសមានចំណូលទាបមកជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ កន្លងទៅ។ ទោះជាយ៉ាងនេះក្ដី គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏នៅតែប្ដេជ្ញាបន្តខិតខំអនុវត្តនូវចក្ខុវិស័យដែលជាគោលដៅសំខាន់ៗ របស់កម្មវិធីកែទម្រង់មួយនេះ ជាពិសេសបញ្ចប់ការងារអាទិភាពដែលនៅសេសសល់ក្នុងអាណត្តិទី៥ និងជំរុញការផ្ដល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ក្រសួង- ស្ថាប័ន។

ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ខ្ញុំសូមសម្ដែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុត ជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្ដេចគឺជា **អគ្គមេបញ្ជាការតែមួយ** ក្នុងការជំរុញកម្មវិធីកែទម្រង់ដ៏មុតស្រួចនេះ ឱ្យទទួលបានលទ្ធផលដ៏ធំធេងគួរជាទីមោទនៈ សម្រាប់គ្រប់ក្រសួង- ស្ថាប័នទាំងអស់។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ និងបន្តគាំទ្រទាំងទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាល, ក្រសួង- ស្ថាប័នដែលជាតួអង្គចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្ត, ព្រមទាំងសហសេវិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕■

ថ្ងៃ ពុធ ០៥ កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**



# អារម្ភកថា

រហូតមកដល់ពេលនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើដំណើរមកដល់ពាក់កណ្ដាលវគ្គនៃដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលត្រូវបានរំពឹងទុកថានឹងត្រូវបញ្ចប់នៅឆ្នាំ២០២០ ខាងមុខ។ តាមរយៈកម្មវិធីកែទម្រង់នេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**) ដែលជាសេនាធិការក្នុងការសម្របសម្រួលការរៀបចំ អនុវត្ត និងតាមដានវាយតម្លៃ បានចូលរួម និងសហការរៀបចំលើឯកសារគោលនយោបាយ, ថវិកា, ការលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមក្នុងកម្មវិធីកែទម្រង់ជាច្រើន។ ជាក់ស្ដែង, ការផ្សព្វផ្សាយតាមរយៈសិក្ខាសាលា, វីដេអូ, ការបណ្ដុះបណ្ដាល, និងព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាដើម។

ជាការពិត ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការប្រមូលផ្ដុំនូវព្រឹត្តិការណ៍សំខាន់ៗដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, អត្ថបទដែលត្រូវបានរៀបចំ និងមានការចូលរួមពីអង្គភាពពាក់ព័ន្ធ ដែលចូលរួមផ្ដល់នូវចំណេះដឹងបន្ថែមសម្រាប់ជាពុទ្ធិ និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ លើកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលសរុបមកដល់ពេលនេះ **អ.គ.ហ.** បានរៀបចំ និងបោះផ្សាយព្រឹត្តិបត្រចំនួន ៥ លេខរួចមកហើយ។ ដោយឡែក សម្រាប់ព្រឹត្តិបត្រលេខ៦ ក៏នឹងរំលេចនូវព្រឹត្តិការណ៍ថ្មីៗ ដែលពាក់ព័ន្ធនឹងកិច្ចប្រជុំរបស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាស និងអត្ថបទពាក់ព័ន្ធនឹងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ជាដើម។ លើសពីនេះ អង្គភាពមួយចំនួន ក៏បានចូលរួមជាអត្ថបទដ៏មានតម្លៃសម្រាប់ជាពុទ្ធិបន្ថែមដល់អ្នកអានដែលជាមន្ត្រីរាជការ និងសាធារណជន សម្រាប់ការសិក្សាស្វែងយល់ និងជ្រាបជាព័ត៌មានបន្ថែម។ ការគាំទ្រទាំងស្មារតី និងអត្ថបទទាំងនេះ ពិតជាបានជំរុញឱ្យក្រុមការងារបន្តការកែលម្អលើការរៀបចំជាបន្តបន្ទាប់។

ជាចុងក្រោយ ខ្ញុំសូមចូលរួមវាយតម្លៃខ្ពស់ជូនចំពោះគ្រប់តួអង្គពាក់ព័ន្ធដែលតែងតែចូលរួម និងគាំទ្រការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមរូបភាពផ្សេងៗ ដែលនេះ គឺជាឧត្តមវិភាគទានសម្រាប់ប្រជាជាតិខ្មែរ។■

ថ្ងៃ អង្គារ ០៣កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៩

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

## ព្រឹត្តិការណ៍


ទំព័រ ០១ — កិច្ចប្រជុំគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពី "ការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសារធារណៈ ប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០១៨”

ទំព័រ ០៥ — កិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តថវិកា ១០ខែ ឆ្នាំ២០១៨ របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ


## អត្ថបទ


ទំព័រ ០៧ — វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ឆ្នាំ២០១៨

ទំព័រ ១១ — យន្តការកែទម្រង់ និងទំនើបកម្មប្រព័ន្ធគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

ទំព័រ ១៣ — ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (Government Finance Statistics)

ទំព័រ ១៦ — ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា÷ការផ្សារភ្ជាប់ការកែទម្រង់ទៅនឹងការផ្តល់សេវាសាធារណៈ

ទំព័រ ២១ — ប្រសិទ្ធភាពនៃការកែលម្អវដ្តថវិកា

ទំព័រ ២៤ — ចំណាយថវិការដ្ឋតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន

ទំព័រ ២៧ — ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

ទំព័រ ២៩ — អ្វីជាសូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicator)?

ទំព័រ ៣៦ — ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ


## ទស្សនៈ និងមតិ


ទំព័រ ៤១ — **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ទំព័រ ៤១ — **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ទំព័រ ៤២ — **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ជ.អ.ប.**

ទំព័រ ៤២ — ឃ្លាដកស្រង់ចេញពីសៀវភៅ Alterative Paths to Public Financial Management and Public Sector Reform ដែលបោះពុម្ពផ្សាយដោយធនាគារពិភពលោក


## សុន្ទរកថា


ទំព័រ ៤៣ — សុន្ទរកថាគន្លឹះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុង “**កម្មវិធីបើកកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**”

ទំព័រ ៥១ — របាយការណ៍បូកសរុបរបស់បណ្ឌិត **ហ៊ែល ចំរើន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង **អ.គ.ហ.** ថ្លែងក្នុង “**កម្មវិធីបិទសិក្ខាសាលាស្តីពី បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា**”




# ផ្នែកទី ១ ÷ ព្រឹត្តិការណ៍

# កិច្ចប្រជុំគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ដីពី "ការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០១៨"

*នាថ្ងៃ អង្គារ ២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០ ព្រឹក នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានរៀបចំកិច្ចប្រជុំគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*

កិច្ចប្រជុំនេះ មានការចូលរួមពី ឯកឧត្ដម លោកជំទាវ ជាសមាជិកគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសហការីសរុបប្រមាណជា ២០០ រូប។

ជាកិច្ចចាប់ផ្ដើម ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានថ្លែងនូវចំណាប់អារម្មណ៍អំពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី១ និងទី២ ក្នុងឆ្នាំ២០១៨ នេះ ថាមានវឌ្ឍនភាពល្អដោយវឌ្ឍនភាពប្រចាំត្រីមាសទី១ សម្រេចបានជារួម៩៧% និងត្រីមាសទី២ សម្រេចបាន ៨៨%។ ត្រីមាសទី២ មានវឌ្ឍនភាពថយចុះជាងត្រីមាសទី១ បន្តិច បណ្ដាមកពីសកម្មភាពដែលបានដាក់ចេញមួយចំនួនពុំសម្រេចបានតាមការគ្រោងទុក។



### ផ្នែកទី១ ÷ ភាពជឿទុកចិត្តនៃថវិកា

យោងតាមរបាយការណ៍បូកសរុបដែលបង្ហាញដោយ **អ.គ.ហ.**, ភាពជឿទុកចិត្តនៃថវិកាក្នុងត្រីមាសទី១ មានវឌ្ឍនភាពល្អប្រសើរដោយសម្រេចបាន៩៨% និងវឌ្ឍនភាពល្អ (៨៩%) ក្នុងត្រីមាសទី២។ វឌ្ឍនភាពនេះ ឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃការអនុវត្តចំណូល និងចំណាយរបស់ក្រសួងតាមផែនការដែលបានគ្រោងទុក។ ជាក់ស្ដែង ការប្រមូលចំណូលសារពើពន្ធ (ចំណូលគយ និងរដ្ឋាករ) និងចំណូលមិនមែនសារពើពន្ធ (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ, និងចំណូលមិនមែនសារពើពន្ធផ្សេង) គិតត្រឹមឆមាសទី១ ធៀបនឹងច្បាប់ថវិកាគឺសម្រេចបានតាមផែនការ ពោលគឺក្នុងរង្វង់៥០%។ ពាក់ព័ន្ធនឹងការអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុវិញ ឃើញថាចំណាយថ្នាក់ជាតិ (ចំណាយចរន្ត និងចំណាយមូលធន) អនុវត្តបាន៤០% និងចំណាយថ្នាក់ក្រោមជាតិអនុវត្តបាន៣៣%។ លទ្ធផលនេះ, អាចសន្និដ្ឋានបានថា ស្ថានភាពសាច់ប្រាក់កាន់តែមានភាពជឿទុកចិត្តបាន និងគ្មានបំណុលកកស្ទះនៅរតនាគារជាតិ (៦០ថ្ងៃ គិតចាប់ពីអាណត្តិបើកផ្ដល់ប្រាក់បានចូលរតនាគារជាតិរហូតដល់ថ្ងៃទូទាត់)។

### ផ្នែកទី២ ÷ គណនេយ្យភាពហិរញ្ញវត្ថុ

ការអនុវត្តក្នុងផ្នែកទី២នេះ, ត្រីមាសទី១ សម្រេចបាន៩៦% និងត្រីមាសទី២ ៩១%។ ជាការកត់សម្គាល់ ក្រសួង-ស្ថាប័នចំនួន១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន២៥ រាជធានី-ខេត្ត បន្ថែមទៀត ត្រូវបានប្រកាសដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធ FMIS និងបានទទួលការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីប្រព័ន្ធ FMIS ផងដែរ។ គិតត្រឹមត្រីមាសទី២ នេះ, អង្គភាពថវិកាចំនួន ៩១១ បានរៀបចំ និងដាក់ឱ្យអនុវត្ត ក្នុងនោះអង្គភាព

*ក្រសួង-ស្ថាប័នចំនួន១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥ រាជធានី-ខេត្តបន្ថែមទៀត ត្រូវបានដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធ FMIS និងទទួលការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីប្រព័ន្ធ FMIS ផងដែរ។*





ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថវិកាចំនួន៣៩ ត្រូវបានដាក់ឱ្យអនុវត្តដល់ក្រសួង-ស្ថាប័ន។ ដោយឡែក ចំណាត់ថ្នាក់ថវិកាទាំង៧ ត្រូវបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS ដែលរួមមាន ÷ ចំណាត់ថ្នាក់រដ្ឋបាល, ភូមិសាស្ត្រ, សេដ្ឋកិច្ច, កម្មវិធី, មុខងារ, គម្រោង និងមូលនិធិ។

### ផ្នែកទី៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយសម្រេចបាន៩៥%នៅត្រីមាសទី១ និង៨៨%នៅត្រីមាសទី២។ ការដាក់ឱ្យអនុវត្តនូវថវិកាកម្មវិធីពេញលេញដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ចាប់ពីឆ្នាំ២០១៨នេះតទៅ គឺជាការសម្រេចបានជាសារវ័ន្តនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ បន្ថែមពីនេះ ការរៀបចំ និងការចរចាថវិកាត្រូវបានពង្រឹង និងកែលម្អមួយកម្រិតខ្ពស់ថែមទៀត ដោយធ្វើការឆ្លុះបញ្ចាំងបានកាន់តែល្អប្រសើរនូវអាទិភាពសំខាន់ៗ របស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចបានគោលបំណង និងគោលនយោបាយរបស់រាជរដ្ឋាភិបាល រួមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត។

### ផ្នែកទី៤ ÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់

វឌ្ឍនភាពក្នុងត្រីមាសទី២ សម្រេចបានត្រឹម៧៧% ជាវឌ្ឍនភាពទាបជាងត្រីមាសទី១ ដែលសម្រេចបាន៩៨% ដោយសារមានសកម្មភាពសំខាន់ៗមួយចំនួនមិនអាចសម្រេចបានតាមការគ្រោង។ ទោះជាយ៉ាងណាក៏ដោយ ក៏មានសកម្មភាពសំខាន់ៗមួយចំនួនផងដែរ ដែលបានលេចរូបរាងឡើង ក្នុងនោះរួមមាន÷ផែនការសកម្មភាព និងសកម្មភាពពាក់ព័ន្ធនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ព្រមទាំងផែនការសកម្មភាពសម្រាប់ការងារកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន រួមទាំងស្ថាប័ននីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ។

### ផ្នែកទី៥ ÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

ជាចំណុចចុងក្រោយ និងជាចំណុចឆ្លុះបញ្ចាំងពីអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ របាយការណ៍បង្ហាញថា វឌ្ឍនាភាពទាំងត្រីមាសទី១ និងត្រីមាសទី២ សម្រេចលើស ៩៥% ដែលជាពិន្ទុក្នុងចំណាត់ថ្នាក់ "ល្អប្រសើរ"។ ការកំណត់សូចនាករមួយចំនួនធំក្នុងផ្នែកនេះ គឺកាន់តែអាចវាស់វែងបាន និងសម្រេចបានតាមពេលវេលាសមស្រម។

*ការដាក់ឱ្យអនុវត្តនូវថវិកាកម្មវិធីពេញលេញដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ចាប់ពីឆ្នាំ២០១៨ នេះ តទៅ គឺជាការសម្រេចបានជាសារវ័ន្តនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។*

### សេចក្តីសន្និដ្ឋាន

តាមរយៈបទបង្ហាញ របាយការណ៍ឆ្លុះបញ្ចាំងអំពីសក្ខីកម្មជាក់ស្តែងនៃការគាំទ្រពីអង្គភាពក្រោមឱវាទ កសហវ ក្នុងការអនុវត្តនូវ GDAP3 ដែលតម្រឹមសកម្មភាពជាមួយសកម្មភាពអាទិភាពនៃ CAP3។ ទន្ទឹមនេះ ការកំណត់ពេលវេលាអនុវត្ត ធនធានមនុស្ស និងការរៀបចំរបាយការណ៍ប្រចាំត្រីមាសនីមួយៗ នៅតែជាបញ្ហាប្រឈម។ ប្រការនេះ ទាមទារឱ្យអង្គភាពក្រោមឱវាទ កសហវ បន្តកិច្ចខិតខំប្រឹងប្រែងបន្ថែម និងបន្តកែលម្អផែនការសកម្មភាពរបស់អង្គភាពនីមួយៗ (GDAP3) ឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងនិម្មាបនកម្មនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេសការគាំទ្រ និងសង្គតិភាពជាមួយផែនការសកម្មភាពរួម (CAP3) និងការកំណត់សូចនាករកាន់តែច្បាស់លាស់ និងអាចវាស់វែងបាន។

ជាកិច្ចបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះរបាយការណ៍ប្រចាំត្រីមាសទី១ និងទី២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរួមចំណែកយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធដែលជាកត្តាលីករជំរុញជវភាពនៃវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនឹងមតិបូកសរុប ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់អង្គភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងស្នើបន្តកិច្ចសហការខ្ពស់ ព្រមទាំងការអនុវត្តឱ្យកាន់តែសកម្មក្នុងទិសដៅដើម្បីបុព្វហេតុ និងឧត្តមប្រយោជន៍នៃប្រទេសជាតិ៕■



# កិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តថវិកា ១០ខែ ឆ្នាំ២០១៨ របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*កាលពីថ្ងៃចន្ទ ០៥កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តថវិកា ១០ខែ ឆ្នាំ២០១៨ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមពីតំណាងអង្គភាពក្រោមឱវាទ **កសហវ.** តំណាងក្រសួង-ស្ថាប័ន មន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញ និងមន្ត្រី របស់ **អ.គ.ហ.**។*

គោលបំណងនៃកិច្ចប្រជុំត្រួតពិនិត្យនេះ គឺ (ទីមួយ) ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានអនុម័តក្នុងឆ្នាំ២០១៨, (ទីពីរ) ត្រៀមរៀបចំលទ្ធផលក្នុងឆ្នាំ និងថវិកាឆ្នាំ២០១៩ សម្រាប់អនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ របស់ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង (ទីបី) ដោះស្រាយនូវកិច្ចប្រឈមលើការអនុវត្តថវិកាកន្លងមករបស់ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជាលទ្ធផល ការអនុវត្តថវិកា ១០ខែ ឆ្នាំ២០១៨ គឺសម្រេចបាន ៨១% ធៀបនឹងថវិកាប្រចាំឆ្នាំ ២០១៨ ដែលមានលម្អិតដូចខាងក្រោម÷

- ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMWG) សម្រេចបាន ៩៣% ធៀបនឹងថវិកាប្រចាំឆ្នាំ២០១៨។
- អង្គភាពក្រោមឱវាទ កសហវ. សម្រេចបាន៦៣% ធៀបនឹងថវិកាប្រចាំឆ្នាំ២០១៨ និង
- ក្រសួង-ស្ថាប័នសម្រេចបាន៧២% ធៀបនឹងថវិកាប្រចាំឆ្នាំ២០១៨។



ជារួម ទោះបីជាការអនុវត្តរបស់អង្គភាពនៅមានលក្ខណៈយឺតយ៉ាវជាងផែនការដែលបានអនុម័តក៏ដោយ ប៉ុន្តែអង្គភាពមួយចំនួនបាននិងកំពុងដំណើរការស្នើសុំសម្រាប់អនុវត្តក្នុងត្រីមាសទី៤ ច្រើនផងដែរ ដូចនេះ **អ.គ.ហ.** មានការជឿជាក់ថានឹងសម្រេចបានតាមគោលដៅក្នុងឆ្នាំផងដែរ និងស្នើសុំការរៀបចំថវិកាឆ្នាំ២០១៩ ឱ្យកាន់តែសុក្រឹត្យ និងមានប្រសិទ្ធភាពបន្ថែមទៀត៕■







ដ្យាក្រាម ÷ ការអនុវត្តថវិកា ១០ខែ ឆ្នាំ២០១៨ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ





ការផ្សារភ្ជាប់ថវិកាទៅនឹង
គោលនយោបាយ
ការគ្រប់គ្រងហិរញ្ញវត្ថុ
សាធារណៈ តាមប្រព័ន្ធ
ព័ត៌មានវិទ្យា
ប្រសិទ្ធភាពនៃ
ការគ្រប់គ្រងសមិទ្ធកម្ម
ប្រសិទ្ធភាពនៃការបែងចែក
ធនធាន និងការគ្រប់គ្រង
ចំណាយ
កម្មវិធីកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុ
សាធារណៈ
ធនធានមនុស្ស
ប្រកបដោយគុណភាព
ប្រសិទ្ធភាពនៃការគ្រប់គ្រង
និងការប្រមូលចំណូល
គុណភាពសេវាសាធារណៈ
និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច


# ផ្នែកទី ២ ៖ អត្ថបទ

# វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ឆ្នាំ២០១៨

*ក្រុមការងារគ្រប់គ្រងគម្រោង FMIS បំពេញការងារប្រកបដោយបុរេសកម្ម និងសម្រេចគោលដៅបានប្រមាណជា៨៨% ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨។ ប្រព័ន្ធ FMIS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្លូវការតែមួយគត់ដែលត្រូវបានប្រើប្រាស់ក្នុងការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកាសម្រាប់រតនាគាររាជធានី-ខេត្តទាំងអស់ចាប់តាំងពីឆ្នាំ២០១៦ ជាមួយនឹងអគ្គនាយកដ្ឋានគន្លឹះៗ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការអនុវត្តគម្រោង FMIS ជំហានទី១។*

ដោយការអនុវត្តប្រព័ន្ធ FMIS ជំហានទី១ ទទួលបានជោគជ័យតាមការគ្រោងទុក, នៅក្នុងឆ្នាំ២០១៧ អគ្គនាយកដ្ឋានរតនាគារជាតិបានឈប់តម្រូវឱ្យរតនាគាររាជធានី-ខេត្តទាំងអស់ផ្ញើរបាយការណ៍ប្រចាំខែមកថ្នាក់កណ្តាលដោយអគ្គនាយកដ្ឋានអាចទាញយករបាយការណ៍តាមតម្រូវការរបស់ខ្លួនពីប្រព័ន្ធ FMIS ដោយផ្ទាល់។ ទន្ទឹមនឹងនេះ គម្រោង FMIS ជំហានទី២ ត្រូវបានបន្តអនុវត្ត និងបានដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់ជាផ្លូវការនៅក្រសួងចំនួន ១០ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១២ កាលពីដើមឆ្នាំ២០១៨។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នចំនួន ១០ បន្ថែម និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥ នឹងត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅដើមឆ្នាំ២០១៩ ខាងមុខ។ ហើយនៅឆ្នាំ២០២០ ប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការបន្តទៀតនៅតាមក្រសួង-ស្ថាប័នដែលនៅសេសសល់ទាំងអស់ ។

## វឌ្ឍនភាព និងជោគជ័យសំខាន់ៗក្នុងការអនុវត្តគម្រោង FMIS

*រតនាគាររាជធានី-ខេត្តទទួលបានប្រព័ន្ធដែលមានប្រសិទ្ធភាពនិងគណនេយ្យភាពក្នុងប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកា។* រតនាគាររាជធានី-ខេត្តទាំង២៥ ឈប់ប្រើប្រាស់ប្រព័ន្ធចាស់ៗដូចជា ប្រព័ន្ធ KIT ជាដើម ដោយប្រើប្រាស់ប្រព័ន្ធ FMIS តែមួយគត់សម្រាប់ធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកា ព្រមទាំងទាញយករបាយការណ៍ហិរញ្ញវត្ថុ និងថវិកាពីប្រព័ន្ធបានភ្លាមៗ ប្រកបដោយភាពជឿជាក់ និងដោយពុំចាំបាច់ផ្ញើឯកសាររបាយការណ៍ហិរញ្ញវត្ថុជាប្រចាំខែមកអគ្គនាយកដ្ឋានរតនាគារជាតិ ដូចពេលពុំទាន់មានប្រព័ន្ធ សម្រាប់ប្រើប្រាស់នោះទេ។ លើសពីនេះ មន្ត្រី និងថ្នាក់ដឹកនាំនៅតាមរតនាគាររាជធានី-ខេត្តទាំងអស់មានលទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងតាមដានប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកាដោយពុំត្រូវការធ្វើការងារស្ទួនគ្នាដដែលៗ។

> *បន្ទាប់ពីទទួលបានជោគជ័យនៅក្នុងជំហានទី១, គម្រោង FMIS ជំហានទី២ ត្រូវបានបន្តអនុវត្ត និងបានដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់ជាផ្លូវការនៅក្រសួងចំនួន១០ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១២ កាលពីដើមឆ្នាំ២០១៨។*

*ចំណាត់ថ្នាក់នៃមាតិកាថវិកាត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធស្ទើរតែទាំងស្រុង។* ចំណាត់ថ្នាក់ទាំង៧ នៃមាតិកាថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងខែមីនា ឆ្នាំ២០១៨ ប៉ុន្តែចំណាត់ថ្នាក់ថវិកាដែលអនុវត្តពេញលេញនាពេលបច្ចុប្បន្ន ទើបតែមាន ៤ ប៉ុណ្ណោះ គឺចំណាត់ថ្នាក់ (១) សេដ្ឋកិច្ច, (២) រដ្ឋបាល, (៣) កម្មវិធី និង (៤) គម្រោង ដោយឡែកចំណាត់ថ្នាក់មុខងារនឹងធ្វើការរៀបចំទាញរបាយការណ៍ដោយការភ្ជាប់ (Code Mapping) ជាមួយចំណាត់ថ្នាក់កម្មវិធី។



*ក្រសួង-ស្ថាប័នមានភាពងាយស្រួលក្នុងការស្នើសុំទូទាត់ចំណាយ និងការកត់ត្រាចំណូលជាតិ។* នៅដើមឆ្នាំ២០១៨ មានក្រសួង-ស្ថាប័នចំនួន១០ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថានចំនួន ១២ បានប្រើប្រាស់ប្រព័ន្ធ FMIS លើមុខងារចំនួន ៤ គឺមុខងារវិភាជន៍ថវិកា, មុខងារទិញ, មុខងារគណនីត្រូវសង និងមុខងារគណនីត្រូវទារ ក្នុងការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ និងថវិការបស់ខ្លួនដែលកាលពីមុនប្រតិបត្តិការទាំងអស់គឺត្រូវបានប្រតិបត្តិក្នុងប្រព័ន្ធ FMIS ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាលទ្ធផលជាក់ស្តែងនៅតាមបណ្តាការដ្ឋានប្រើប្រាស់ប្រព័ន្ធ FMIS ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានការកើនឡើងនៃចំនួនប្រតិបត្តិការ, ល្បឿន និងការកែសម្រួលនូវនីតិវិធី ឬរបៀបរបបធ្វើការងារមានលក្ខណៈល្អប្រសើរជាងមុន។ ចំពោះការទូទាត់ចំណាយ, ក្រសួងនិងអង្គភាពថវិកាផ្ទេរសិទ្ធិពេញលេញធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយផ្ទាល់នៅក្នុងប្រព័ន្ធ FMIS រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលធ្វើឱ្យព័ត៌មាន ឬទិន្នន័យមានសង្គតិភាព, រហ័សលើការចំណាយទូទាត់ត្រង់ ដោយពុំព្រួយបារម្ភពីបញ្ហាខ្វះឥណទានថវិកា និងបញ្ចៀសបាននូវការធ្វើការងារត្រួតគ្នាដដែលៗ ចាប់ពីពេលស្នើសុំទូទាត់រហូតដល់ធ្វើការទូទាត់សាច់ប្រាក់។ ជាងនេះទៀត ក្រសួង និងអង្គភាពថវិកាផ្ទេរសិទ្ធិទាំងនោះ មានលទ្ធភាពទាញយករបាយការណ៍ហិរញ្ញវត្ថុ និងថវិកាមកប្រើប្រាស់បានតាមតម្រូវការរបស់ខ្លួនយ៉ាងឆាប់រហ័ស និងងាយស្រួល។ ចំណែកឯការកត់ត្រាចំណូលថវិកាជាតិក៏កាន់តែមានភាពច្បាស់លាស់ក្នុងការកំណត់មុខសញ្ញាចំណូល និងបានឆាប់រហ័សជាងមុន ជាពិសេសតាមរយៈការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ ASYCUDA និង E-Customs និងប្រព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជជាដៃគូនានា។

*មានមូលដ្ឋានគ្រឹះរឹងមាំក្នុងការកាត់បន្ថយនីតិវិធីអនុវត្តការងារ។* ប្រព័ន្ធ FMIS ត្រូវបានរៀបចំ និងអភិវឌ្ឍតាមលក្ខណៈស្តង់ដារអន្តរជាតិ ដោយមានការសិក្សា និងចងក្រងនីតិវិធីអនុវត្តការងារបានច្បាស់លាស់។ ដើម្បីសម្រួលការអនុវត្តការងារហិរញ្ញវត្ថុ និងថវិការបស់រាជរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ក្នុងកិច្ចប្រជុំស្តីពីវឌ្ឍនភាព, បញ្ហាប្រឈម និងផែនការអនុវត្តគម្រោង FMIS ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់អនុសាសន៍ជាអភិក្រមក្នុងការបន្តអនុវត្តគម្រោង FMIS ដូចជា÷

- រៀបចំសិក្សាកាត់បន្ថយនីតិវិធីអនុវត្តការងារធ្វើដោយដៃនិងឈានទៅអនុវត្តនីតិវិធីក្នុងប្រព័ន្ធ FMIS ទាំងស្រុងដោយគិតគូរលើក្រសួងស្ថាប័នដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS និងផ្តោតលើមុខចំណាយណាដែលមានហានិភ័យទាប ឬមិនមានហានិភ័យក្នុងការចាយខុស រួមជាមួយនឹងការត្រៀមរៀបចំវគ្គបណ្តុះបណ្តាល, រៀបចំពង្រាយមន្ត្រីទៅតាមមុខងារប្រព័ន្ធ FMIS ឬនីតិវិធីអនុវត្តការងារថ្មី និងរៀបចំផែនការគ្រប់គ្រងការផ្លាស់ប្តូរច្បាស់លាស់ពីពេលនេះរហូតដល់ឆ្នាំ២០២០។
- អគ្គនាយកដ្ឋានពាក់ព័ន្ធត្រូវសហការ



ដោះស្រាយបញ្ហាបច្ចេកទេសនានាក្នុងប្រព័ន្ធ រួមទាំងគុណភាពទិន្នន័យ ដើម្បីធានាឱ្យបាននូវការបិទបញ្ជីប្រចាំឆ្នាំ ២០១៨ នៅឆ្នាំ២០១៩ តាមប្រព័ន្ធ FMIS ដោយពុំចាំបាច់ផ្ទៀងផ្ទាត់របាយការណ៍ខាងក្រៅ និងពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង ៧ ឱ្យបានពេញលេញ។

- មុខងារថ្មីចំនួន ២ ដែលត្រូវអភិវឌ្ឍសម្រាប់ប្រព័ន្ធ FMIS គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម។

*ជារួមការអនុវត្តគម្រោង FMIS មកដល់ពេលនេះ បានកំពុងធានាជាបណ្តើរៗ នូវការសម្រេចបានទិសដៅរួមសំខាន់ៗ ចំនួន៣ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ៖*

- ការពង្រឹងវិន័យថវិកា រួមមាន (១) ផែនការថវិកាសម្រាប់រជ្ជទេយ្យបុរេប្រទានត្រូវបានញែក និងចែកដាច់ច្បាស់ពីថវិកាទូទៅ (២) មានផែនការ និងឥណទានថវិកាត្រូវតាមមុខចំណាយ និងកម្មវិធីទើបអាចចាយបាន, (៣) សម្រាប់ចំណាយតាមកិច្ចលទ្ធកម្មគឺត្រូវមានព័តិមានច្បាស់លាស់តាំងពីការធានាចំណាយ, ព័តិមានកិច្ចសន្យា, ព័តិមានអ្នកផ្គត់ផ្គង់ត្រឹមត្រូវ, ព័តិមានស្តីពីការប្រគល់ទទួល និងសក្ខីបត្រត្រឹមត្រូវទើបអាចឆ្លងដល់ការទូទាត់បាន និង (៤) ការទូទាត់ត្រូវបានជំរុញឱ្យទូទាត់ផ្ទាល់ទៅអ្នកទទួលផលចុងក្រោយលើកលែងតែការទូទាត់រជ្ជទេយ្យបុរេប្រទាន។
- ការបង្កើនប្រសិទ្ធភាពវិភាជន៍ថវិកា៖ ថវិកាតម្រូវឱ្យធ្វើការវិភាជទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា និងចំណាយត្រូវតាមមុខចំណាយច្បាស់លាស់ស្របតាមកម្មវិធី និងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងនៅថ្ងៃអនាគត ប្រព័ន្ធនឹងធ្វើសន្ទានកម្មក្នុងការទទួលបាននូវសូចនាករសមិទ្ធកម្ម ដើម្បីគ្រប់គ្រង និងតាមដានសមិទ្ធកម្មថវិកា (ដោយប្រើប្រាស់ Data Warehouse និង Business Intelligence)។







*ចំពោះការទូទាត់ចំណាយ, ក្រសួង និងអង្គភាពថវិកាផ្ទេរសិទ្ធិពេញលេញធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយផ្ទាល់នៅក្នុងប្រព័ន្ធ FMIS រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលធ្វើឱ្យព័តិមាន ឬទិន្នន័យមានសង្គតិភាព និងរហ័សលើការចំណាយទូទាត់ត្រង់។*

- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ៖ ផ្តល់នូវទិន្នន័យ និងព័តិមាននៃការគ្រប់គ្រង និងអនុវត្តថវិកាគ្រប់ជ្រុងជ្រោយប្រកបដោយភាពច្បាស់លាស់, ជាក់ស្តែង និងទាន់ពេលវេលា ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធី, លទ្ធផល និងសមិទ្ធកម្ម "One vision of the truth"៕■



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យន្តការកែទម្រង់ និងទំនើបកម្មប្រព័ន្ធគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

*អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការលើកិច្ចការគ្រប់គ្រងបុគ្គលិកមន្ត្រីរាជការរបស់ក្រសួង មានឆន្ទៈមោះមុត ក្នុងការសម្របសម្រួលគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន តាមរយៈការប្រែក្លាយមូលធនមនុស្សក្រោមឱវាទក្រសួង ឱ្យកាន់តែមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ ផ្អែកលើសមិទ្ធកម្ម និងបច្ចេកវិទ្យា ជាពិសេសការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ប្រកបដោយផលិតភាព និងប្រសិទ្ធភាព។*

ស្ថិតក្នុងបរិការណ៍នៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងនវានុវត្តន៍បច្ចេកវិទ្យា ដែលជាកត្តាចម្បងក្នុងការកំណត់នូវនិន្នាការវិវឌ្ឍសង្គម-សេដ្ឋកិច្ចស្របតាមឧត្តមានុវត្តន៍អន្តរជាតិ, បច្ចុប្បន្ននេះ ការធ្វើទំនើបកម្មប្រព័ន្ធការងារបានក្លាយជាចំណុចគន្លឹះក្នុងការជំរុញល្បឿននៃស្វ័យប្រវត្តិកម្មការងារ ដែលអាចជំនួសកម្លាំងធនធានមនុស្ស ជាពិសេសការសម្រួលការងារដោយបច្ចេកវិទ្យាព័ត៌មាន ជំនួសឱ្យការបំពេញមុខងារដោយដៃ ប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែង ផ្អែកតាមផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៨ នៃកម្មវិធីកែទម្រង់, អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំក្របខណ្ឌគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សឆ្នាំ២០១៨-២០២៣ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈប្រកាសលេខ ១៦១១ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ សម្រាប់អនុវត្តក្នុងអាណត្តិទី៦ ដែលមានចក្ខុវិស័យផ្តល់អាទិភាពខ្ពស់លើការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ ដោយផ្តោតសំខាន់លើការជំរុញការធ្វើទំនើបកម្មប្រព័ន្ធបៀវត្សដើម្បីកាត់បន្ថយនីតិវិធីស្មុគស្មាញ និងបញ្ចៀសការពិនិត្យ និងផ្ទៀងផ្ទាត់តារាងបៀវត្សដោយដៃ ហើយអង្គភាពបៀវត្សត្រូវតម្រង់ទិសលើការប្រើប្រាស់ព័ត៌មានវិទ្យា ជាពិសេសការគ្រប់គ្រងប្រសិទ្ធភាពកិច្ចការបៀវត្ស និងត្រួតពិនិត្យការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការឱ្យទាន់ពេលវេលា សំដៅផ្តល់ការលើកទឹកចិត្ត ធានាសុក្រឹតភាព សង្គតិភាព ភាពទៀងទាត់ និងទាន់ពេលវេលានៃការបើកបៀវត្សតាមប្រព័ន្ធធនាគារ។ ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន បាននិងកំពុងអនុវត្តនូវយន្តការមួយចំនួន រួមមាន÷ ការគ្រប់គ្រងស្ថានភាពមន្ត្រីរាជការដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, រៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិករួមមួយច្បាស់លាស់ ក្នុងកិច្ចការរៀបចំដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងរៀបចំដំឡើងថ្នាក់-ឋានន្តរស័ក្តិ ដោយមានប្រព័ន្ធក្រើនរំលឹកស្តីពីចំនួន និងកាលបរិច្ឆេទមន្ត្រីរាជការត្រូវចូលនិវត្តន៍ ជាដើម។ បន្ថែមពីនេះ កិច្ចការចាំបាច់សម្រាប់ទៅថ្ងៃអនាគតក៏ត្រូវគិតគូរអំពីការពង្រឹងកិច្ចដំណើរការប្រព័ន្ធផ្តល់ព័ត៌មានបៀវត្ស និងបណ្តឹងតវ៉ា ព្រមទាំងបង្កើតយន្តការអនុវត្តគោលនយោបាយកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយកែលម្អ និងពង្រឹងការអនុវត្តយន្តការគ្រប់គ្រងបញ្ជីបៀវត្សរបស់មន្ត្រីរាជការក្រសួង។






គិតពីឆ្នាំ២០១០ ក្រសួងបានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការដែលហៅកាត់ថា HRMIS ដោយត្រូវបានប្រើប្រាស់សម្រាប់គ្រប់គ្រងមន្ត្រីរាជការជាង ៤ ០០០ នាក់ និងបានកើនឡើងដល់ចំនួន ៥ ២៧១ នាក់ នៅឆ្នាំ២០១៣។ ប្រព័ន្ធនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅតាមការិយាល័យជំនាញទទួលបន្ទុកកិច្ចការបៀវត្ស, ត្រួតពិនិត្យវត្តមាន និងវិន័យបុគ្គលិក, គ្រប់គ្រងការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្ស នៃអគ្គលេខាធិការដ្ឋាន ដើម្បីត្រួតពិនិត្យ គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពនូវចលនាប្រែប្រួលទិន្នន័យមន្ត្រីរាជការពាក់ព័ន្ធប្រវត្តិការងារ គ្រឿងឥស្សរិយស ស្ថានភាពការងារ ព័ត៌មានគ្រួសារ ចំណេះដឹងទូទៅ និងជំនាញ ជាដើម។ ប្រព័ន្ធនេះអនុញ្ញាតឱ្យអង្គភាពជំនាញពិនិត្យផ្ទៀងផ្ទាត់ កែតម្រូវ និងទាញយកទិន្នន័យជាទម្រង់របាយការណ៍បានក្នុងកម្មវិធី Ms Word និង Ms Excel។ ដោយឡែក ប័ណ្ណសម្គាល់មន្ត្រីរាជការ ត្រូវបានសហការជាមួយក្រុមហ៊ុនឯកជន ដើម្បីធ្វើការបោះពុម្ពជូនមន្ត្រីរាជការ។



បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានក្រសួងបានធ្វើបច្ចុប្បន្នភាព និងធ្វើទំនើបកម្មប្រព័ន្ធ HRMIS តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យ ជួយសម្រួល និងពន្លឿនប្រសិទ្ធភាពការងារដោយរៀបចំឱ្យមាន÷

- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការជារួមរបស់ក្រសួង ព័ត៌មានស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង មុខងារ ឋានានុក្រម និងទិន្នន័យចំនួនថ្នាក់ដឹកនាំ មន្ត្រី ភ្នាក់ងារ,
- ប្រព័ន្ធគ្រប់គ្រង និងផ្ទុកឯកសារ, ប្រវត្តិរូបបុគ្គលិកមន្ត្រីរាជការ ជាទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលអនុញ្ញាតឱ្យមន្ត្រីពិនិត្យ និងទាញយកព័ត៌មានផ្ទាល់ខ្លួន បានយ៉ាងលម្អិត និងជាមូលដ្ឋានសំខាន់ក្នុងការគ្រប់គ្រងបម្រែបម្រួលស្ថានភាពមន្ត្រី ជាពិសេសការគ្រោងក្របខណ្ឌសម្រាប់ផែនការធនធានមនុស្ស,
- កាតមន្ត្រីរាជការនៃគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវបានបោះពុម្ពដោយនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួង,
- តភ្ជាប់ប្រព័ន្ធបណ្តឹងតវ៉ាទាក់ទងនឹងបៀវត្ស ដែលសាមីមន្ត្រីអាចចូលមើលគណនីផ្ទាល់ខ្លួន និងចោទជាសំណួរ ឬមតិយោបល់តាមប្រព័ន្ធអនឡាញ (Online) និង
- ផ្តល់គណនីប្រើប្រាស់ (User Account ដល់មន្ត្រីរាជការក្រោមឱវាទក្រសួង ដោយមានស្កេនឯកសារភ្ជាប់ជាមួយប្រវត្តិរូប។

*អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរួចរាល់នូវក្របខណ្ឌគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់អនុវត្តក្នុងអាណត្តិទី៦ ដែលមានចក្ខុវិស័យផ្តល់អាទិភាពខ្ពស់លើការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ។*

ទន្ទឹមនឹងការវិវឌ្ឍលើប្រព័ន្ធគ្រប់គ្រងបុគ្គលិកនេះ អគ្គលេខាធិការដ្ឋានបាននិងកំពុងគិតគូរអំពីការជំរុញការធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ឱ្យកាន់តែមានសង្គតិភាព ដើម្បីសម្រួលដល់ការផ្ទៀងផ្ទាត់ទិន្នន័យក្នុងការរៀបចំបៀវត្ស ព្រមទាំងពង្រឹងកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សំដៅធានាប្រសិទ្ធភាពការងារ ជាពិសេសកិច្ចការរៀបចំ គ្រប់គ្រងផ្ទៀងផ្ទាត់ ការធ្វើនិយ័តកម្ម ការពិនិត្យសំណើសុំ និងផ្តល់ទិដ្ឋាការ ជាដើម៕■

# ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (Government Finance Statistics)

*ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) ជាស្ថិតិស្តង់ដារអន្តរជាតិមួយសម្រាប់រៀបចំស្ថិតិហិរញ្ញវត្ថុវិស័យរដ្ឋាភិបាល និងវិស័យសាធារណៈ។*

ស្ថិតិនេះ ផ្តល់នូវព័ត៌មានហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងវិស័យសាជីវកម្មសាធារណៈគ្រប់ជ្រុងជ្រោយទាំងទិដ្ឋភាពចំណូល, ចំណាយ, ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលដែលមានលក្ខណៈងាយយល់ និងងាយប្រើប្រាស់ប្រកបដោយសង្គតិភាពជាមួយបណ្តាប្រទេសជាង ១៨៩។ ស្តង់ដារស្ថិតិនេះ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំងក្របខណ្ឌជាតិ (Cambodia SDGs) និងក្របខណ្ឌរបស់អង្គការសហប្រជាជាតិ (UN SDGs) លើសូចនាករចំនួន២[១] នៃគោលដៅទី១៧ ស្តីពីភាពជាដៃគូដើម្បីសម្រេចគោលដៅ។ ជាមួយគ្នានេះ ស្ថិតិ GFS ត្រូវបានអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងស្ថាប័នវាយតម្លៃចំណាត់ថ្នាក់អន្តរជាតិប្រើប្រាស់ជាធាតុចូលក្នុងក្របខណ្ឌវាយតម្លៃតម្លាភាព (Transparency Architecture Codes) នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។ ចំពោះផ្នែកសេដ្ឋកិច្ចវិញ ប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) បានដើរតួនាទីជាធាតុចូលយ៉ាងសំខាន់មួយដែលមិនអាចខ្វះបានសម្រាប់ការរៀបចំប្រព័ន្ធស្ថិតិនៃវិស័យពិត (real sector statistics), វិស័យក្រៅប្រទេស (external sector Statistics), និងវិស័យរូបិយវត្ថុ និងហិរញ្ញវត្ថុ (monetary and finance statistics) និងជាវិស័យស្ថិតិមួយ ដែលបំពេញក្នុងប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះ ស្ថិតិ GFS គឺជាមូលដ្ឋានស្ថិតិចាំបាច់សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នជាតិ និងអន្តរជាតិនានា ប្រើប្រាស់ក្នុងការវិភាគ និងវាយតម្លៃស្ថានភាព និងរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ ជារួម វាជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការសម្រេចចិត្តសម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងការតាមដានវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តជាប្រចាំស្របតាមអភិក្រមស្ថិតិ “*គោលនយោបាយល្អប្រសើរ អាស្រ័យលើគុណភាពស្ថិតិ, Better Data Better Policy*”។

ក្នុងន័យនេះ ការអនុវត្តប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រកបដោយភាពពេញលេញ បានក្លាយជារបៀបវារៈមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានភាពប្រទាក់ក្រឡា និងគាំទ្រគ្នាទៅវិញទៅមកជាមួយនឹងការកែទម្រង់នៃផ្នែកផ្សេងៗទៀត ដែលស្ថិតិនៅក្រោមឆត្រនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។




ផ្អែកលើស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (Government Finance Statistics Manual _GFSM) នេះ បានកំណត់យ៉ាងច្បាស់នូវនិយមន័យ និងវិធីសាស្ត្ររៀបចំស្ថិតិប្រកបដោយសង្គតិភាព និងភាពប្រទាក់ក្រឡា ដែលត្រូវបានយកទៅប្រើប្រាស់សម្រាប់ធាតុចូលនៃប្រព័ន្ធស្ថិតិគណនីជាតិ, ស្ថិតិជញ្ជីងទូទាត់, និងស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ។ និយមន័យសំខាន់ៗដែលបានកំណត់ក្នុងប្រព័ន្ធស្ថិតិនេះមានដូចជា÷




**ចំណូល** គឺជាប្រតិបត្តិការទាំងឡាយណា (transactions) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន÷ ចំណូលពន្ធ, ចំណូលពីការចូលរួមសង្គម, ចំណូលពីអំណោយ និងចំណូលផ្សេងៗ។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច (ជម្រះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះ គឺការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ) ហើយទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរ សម្រាប់ប្រាក់កម្ចីដែលទទួលបាន ឬការសងបំណុលដែលគេជំពាក់ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

**ចំណាយ** គឺជាប្រតិបត្តិការទាំងឡាយណា (transactions) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗ នៃចំណាយរួមមាន÷ ចំណាយបៀវត្ស និងលាភការ, ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម, ចំណាយលើការប្រាក់, ចំណាយលើការឧបត្ថម្ភធន, ចំណាយលើការផ្តល់អំណោយ, ចំណាយលើឧបត្ថម្ភសង្គមកិច្ច, និងចំណាយផ្សេងៗ។ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរដូចជា÷ចំណាយលើមុខងារសេវាកម្មសាធារណៈទូទៅ, ចំណាយលើមុខងារការពារជាតិ, ចំណាយលើមុខងារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ, ចំណាយលើមុខងារកិច្ចការសេដ្ឋកិច្ច, ចំណាយលើមុខងារកិច្ចការបរិស្ថាន, ចំណាយលើមុខងារការរៀបចំលំនៅដ្ឋាន និងការគ្រប់គ្រងសហគមន៍, ចំណាយលើមុខងារកិច្ចការសុខាភិបាល, ចំណាយលើមុខងារកម្សាន្ត កីឡា សិល្បៈ វប្បធម៌ ផ្សព្វផ្សាយ និងសាសនា, ចំណាយលើមុខងារអប់រំ, និងចំណាយលើមុខងារគាំពារសង្គម។ ចំពោះការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះ គឺការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរ សម្រាប់ប្រាក់កម្ចីដែលបានសងក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

**តុល្យភាពប្រតិបត្តិការសុទ្ធ** គឺជាផលសងនៃចំណូលដកសរុបចំណាយ។ ហើយវាអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំ និងមូលនិធិផ្ទេរដែលត្រូវទទួល។ តុល្យភាពប្រតិបត្តិការសុទ្ធនៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពីការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume) ទ្រព្យសកម្ម ឬបំណុលឡើយ។

*ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលគឺជាមូលដ្ឋានស្ថិតិចាំបាច់សម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នជាតិ និងអន្តរជាតិ ប្រើប្រាស់ក្នុងការវិភាគ និងវាយតម្លៃស្ថានភាព និងរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។*

**តុល្យភាពប្រតិបត្តិការដុល** មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់ (រំលស់) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។

[១] សូចនាករ១៧.១.១. ចំណូលរដ្ឋាភិបាលធៀបនឹងផលិតផលក្នុងស្រុកសរុប (តាមប្រភេទចំណូល) និងសូចនាករ១៧.១.២. សមាមាត្រនៃថវិកាក្នុងស្រុកដែលមានប្រភពពីចំណូលពន្ធ។

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានរតនាគារជាតិនៅមិនទាន់អាចគណនាចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុបាននៅឡើយទេ ស្របពេលដែលវិទ្យាស្ថានជាតិស្ថិតិបានសន្មត់ចំណាយនេះក្នុងរង្វង់១៥% នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។

*ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលត្រូវបានអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នវាយតម្លៃចំណាត់ថ្នាក់អន្តរជាតិប្រើប្រាស់ជាធាតុចូលក្នុងក្របខណ្ឌវាយតម្លៃតម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។*

**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** ជាលទ្ធផលនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានទិញក្រោយដកចេញការលក់ (ជម្រះបញ្ជី) និងចំណាយប្រើប្រាស់ (រំលស់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរួមមាន÷អចលនទ្រព្យ មានអគារ និងសំណង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ, ម៉ាស៊ីន និងសម្ភារបរិក្ខារ, និងទ្រព្យសកម្មផ្សេងៗ, សន្និធិ, ទ្រព្យសម្បត្តិមានតម្លៃ, និងទ្រព្យសកម្មគ្មានផលិតភាព។

**ចំណាយសរុប** (expenditure) គឺជាផលបូកដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ) លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះ បានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ និងមានភាពសមស្រប (សង្គតិភាព) សម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ។

**តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** ជាលទ្ធផលនៃផលសងនៃចំណូល និងចំណាយសរុប។ សមតុល្យនេះ ក៏បង្ហាញឱ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុទៅវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឱ្យខ្ចី) ឬការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទានពីវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

**ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល** ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា÷ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលប័ត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ៕■



# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្ពុជា ÷ ការផ្សារភ្ជាប់ការកែទម្រង់ទៅនឹងការផ្តល់សេវាសាធារណៈ[1]

*ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជួយឱ្យរដ្ឋាភិបាលគ្រប់គ្រងលំហូរនៃធនធានពីប្រភពនានា ទៅគ្រប់ក្រសួង-ស្ថាប័នរួមបញ្ចូលទាំងវិស័យកសិកម្ម វិស័យសុខាភិបាល និងវិស័យអប់រំ ព្រមទាំងផ្តល់នូវសេវាវិនិយោគសាធារណៈ ដើម្បីធានាសន្តិសុខសង្គម ស្ថិរភាព និងកំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន។*

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខ្សោយ បង្កឱ្យមានការរាំងស្ទះដល់ការផ្តល់សេវាសាធារណៈជាទូទៅ។ ឧទាហរណ៍ ភាពមិនគ្រប់គ្រាន់នៃថវិកា អាចនាំឱ្យមានកង្វះខាតក្នុងការផ្តល់សេវា ហើយប្រសិនបើមានថវិកា ប៉ុន្តែការរៀបចំស្ថាប័នដែលមានស្រាប់មិនមានភាពរឹងមាំ អាចនឹងមិនជំរុញការប្រើប្រាស់ធនធានសាធារណៈ ប្រកបដោយប្រសិទ្ធភាពនោះឡើយ។ លើសពីនេះទៅទៀត កង្វះគណនេយ្យភាពរបស់អ្នកគ្រប់គ្រងចំណាយ អាចធ្វើឱ្យការប្រើប្រាស់សម្បត្តិសាធារណៈមិនចំគោលដៅ។




## ចក្ខុវិស័យសម្រាប់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា

ដោយទទួលស្គាល់នូវសារៈសំខាន់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំពោះការផ្តល់សេវាសាធារណៈ, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលវែងគិតចាប់តាំងពីឆ្នាំ២០០៤ មក។ កម្មវិធីកែទម្រង់នេះ ជួយស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាប្រឈមដែលកើតមានពីភាពខ្សោយនៃប្រព័ន្ធដោយផ្អែកលើវិធីសាស្ត្រកសាងនូវការអនុវត្តជាជំហានៗ (Platform approach) ដែលចែកចេញជា៤ ដំណាក់កាល។ ដំណាក់កាលទាំង៤ នៃកម្មវិធីកែទម្រង់នេះ រួមមាន (១) ការកែលម្អភាពជឿទុកចិត្តនៃថវិកា (ការប្រមូល និងគ្រប់គ្រងចំណូល ព្រមទាំងការរៀបចំ និងគ្រប់គ្រងសាច់ប្រាក់) ដែលត្រូវបានបញ្ចប់ក្នុងឆ្នាំ២០០៨ (២) ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ដោយផ្តោតលើការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលចាប់ផ្តើមនៅឆ្នាំ២០០៩ និងបញ្ចប់នៅឆ្នាំ២០១៥ (៣) ការកែលម្អការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការអនុវត្តនូវថវិកាកម្មវិធី ដែលចាប់ផ្តើមនៅឆ្នាំ២០១៥ ហើយនឹងបញ្ចប់នៅក្នុងឆ្នាំ២០២០ (៤) ការកែលម្អគណនេយ្យភាពចំពោះការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទាំងមូល ដែលនឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០២១ និងបញ្ចប់នៅឆ្នាំ២០២៥។

*តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានសម្រេចនូវការបោះជំហានដ៏ជោគជ័យក្នុងការកសាងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំកម្រិតថ្នាក់ជាតិ។*

ឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ របស់រាជរដ្ឋាភិបាល បានបង្ហាញឱ្យឃើញពីទិសដៅនៃប្រព័ន្ធថវិកា ដែល (១) ការរៀបចំថវិកា ត្រូវផ្អែកលើផែនការ

[1] អត្ថបទនេះ គឺជាការយល់ឃើញទាំងស្រុងរបស់អ្នកនិពន្ធ។ វាមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ធនាគារពិភពលោក និងបណ្តាញអង្គការផ្សេងទៀត ឬថ្នាក់ដឹកនាំរបស់ធនាគារពិភពលោក ឬរដ្ឋាភិបាលផ្សេងទៀតដែលតំណាងដោយធនាគារពិភពលោកនោះទេ។ ចូលរួមដោយ ស៊ូ សុខប៊ុនធឿន ជាមន្ត្រីជំនាញជាន់ខ្ពស់វិស័យសាធារណៈនៃធនាគារពិភពលោក។

យុទ្ធសាស្ត្រថវិកា ៣ ឆ្នាំរំកិល របស់ក្រសួងស្ថាប័ន (២) ការអនុម័តថវិកាផ្តោតលើគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករ (៣) ការអនុវត្តថវិកាផ្អែកលើការធ្វើប្រតិភូកម្មអំណាចសមរម្យដែលអាចឆ្លើយតបនឹងថវិកាផ្អែកលើសមិទ្ធកម្ម (៤) ការអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

*តើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអ្វី? ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាប្រព័ន្ធដែលធនធានហិរញ្ញវត្ថុត្រូវបានរៀបចំ គ្រប់គ្រង តាមដាន និងត្រួតពិនិត្យដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។*

ទិសដៅយុទ្ធសាស្ត្រនៃប្រព័ន្ធថវិកាកម្ពុជាត្រូវបានបង្ហាញកាន់តែច្បាស់ និងស៊ីជម្រៅនៅក្នុងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ គោលបំណងនៃឯកសារនេះ ចង្អុលបង្ហាញថាប្រព័ន្ធថវិកាកម្ពុជា នឹងផ្តោតលើថវិកាកម្មវិធីជាមួយនឹងគោលនយោបាយកម្មវិធីគ្រប់ជ្រុងជ្រោយ ការផ្សារភ្ជាប់ថវិកា និងគណនេយ្យភាពសមិទ្ធកម្ម។ ថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម (Performance informed budgeting) សំដៅដល់ធនធានដែលត្រូវបានបែងចែក ដោយមានការពាក់ព័ន្ធមិនផ្ទាល់ទៅនឹងសមិទ្ធកម្មអនាគត ឬអតីតកាលត្រូវបានអនុម័តសម្រាប់ការអនុវត្តការកែទម្រង់ថវិកា។ ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង នឹងត្រូវពង្រឹងដើម្បីទ្រទ្រង់ដល់ការផ្លាស់ប្តូរនេះ។ ការអនុវត្តយុទ្ធសាស្ត្រនេះ បានជោគជ័យ អាចជួយដល់កិច្ចដំណើរការថវិកាប្រកបដោយតម្លាភាពជាមួយនឹងប្រព័ន្ធរបាយការណ៍ទាន់ពេលវេលាស្របតាមស្តង់ដារអន្តរជាតិ។

ជាសរុប ឯកសារគោលនយោបាយកែទម្រង់ទាំងអស់នេះ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលរំកិលទៅរកប្រព័ន្ធទូទាត់តាមបែបមជ្ឈការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបែបវិមជ្ឈការ។




ប្រព័ន្ធទូទាត់តាមបែបមជ្ឈការ ÷ ប្រព័ន្ធទូទាត់តាមបែបមជ្ឈការ ស្ថិតក្រោមគណនីទោលរតនាគារ (TSA) មានន័យថារាល់ចំណាយទាំងអស់ ត្រូវបានគ្រប់គ្រងជារួមពីថ្នាក់កណ្តាល តាមរយៈការភ្ជាប់គ្នានៃគណនីធនាគារដែលអាចប្រើប្រាស់ធនធានរួមដែលមាននៅក្នុងគណនីទោលរតនាគារ។ ប្រព័ន្ធនេះ អនុញ្ញាតឱ្យរដ្ឋាភិបាលតាមដានលើធនធានហិរញ្ញវត្ថុទាំងអស់ និងមានកំណត់ត្រានៃធនធានហិរញ្ញវត្ថុដែលត្រូវបានប្រើប្រាស់ដោយគ្រប់ជ្រុងជ្រោយ។

ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ÷ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបែបវិមជ្ឈការកម្រិតវិស័យ និងអង្គភាពថវិកា ផ្តល់អំណាចគ្រប់គ្រាន់សម្រាប់អង្គភាពដែលផ្តល់សេវាសាធារណៈដោយផ្អែកលើលទ្ធផលតាមគោលនយោបាយក្នុងវិស័យទាំងមូល។ ពេលដែលប្រព័ន្ធ FM-IS ត្រូវបានអនុវត្តពេញលេញជាមួយនឹងការកែលម្អ និងតម្រង់ទិសនីតិវិធីអនុវត្តការងារ នោះបញ្ហាលំហូរសាច់ប្រាក់ នឹងលែងក្លាយជាបញ្ហាប្រឈមសម្រាប់ការទូទាត់ចំណាយ ដែលនឹងត្រូវធ្វើដោយផ្ទាល់ពីប្រភពតែមួយ (គណនីទោលរតនាគារ)។

ប្រព័ន្ធទូទាត់តាមបែបមជ្ឈការ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ÷ ក្របខណ្ឌសម្រាប់ទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានេះ បង្ហាញពីរបត់អន្តរកាលដ៏ធំមួយឆ្ពោះទៅរកលទ្ធផល និងចាកចេញពីកិច្ចដំណើរការដែលប្រើប្រាស់ដោយក្រដាស នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដំណើរការថ្មីនេះ អាចផ្តល់ឱ្យមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវពេលវេលាសម្រាប់ផ្តោតលើការពង្រឹងគោលនយោបាយ ការប្រមូលចំណូលបន្ថែម ដើម្បីធានាភាពគ្រប់គ្រាន់នៃធនធាន សម្រាប់ការអនុវត្តកម្មវិធី និងការផ្តល់សេវាដល់ប្រជាពលរដ្ឋ ការពង្រឹងផែនការសាច់ប្រាក់ (ការព្យាករ និងការគ្រប់គ្រង) និងគោលនយោបាយវិនិយោគ។ នៅពេលអនុវត្តបានជោគជ័យ ប្រព័ន្ធនេះ នឹងសម្រួលដល់ការផ្តល់សេវាសាធារណៈ ព្រមទាំងធានានូវការគ្រប់គ្រងធនធានទាំងអស់ប្រកបដោយប្រសិទ្ធភាព។ មកដល់បច្ចុប្បន្ននេះ ការអនុវត្តត្រូវបានរៀបចំជាជំហានៗសម្រាប់ការខិតទៅរកប្រព័ន្ធទំនើបនេះ។

## សមិទ្ធផល

តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចនូវការបោះជំហានដ៏ជោគជ័យក្នុងការកសាងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រឹងមាំកម្រិតថ្នាក់ជាតិ។ សមិទ្ធផលសំខាន់ៗ រួមមាន (១) ការប្រមូលចំណូលគួរឱ្យកត់សម្គាល់ ដោយបានជំរុញកំណើននៃការប្រមូលចំណូលពី ១០,៣ ភាគរយធៀបនឹង ផ.ស.ស. ក្នុងឆ្នាំ២០០៤ មក ១៩,៧ ភាគរយ ក្នុងឆ្នាំ២០១៧ (២) ការលុបបំបាត់ពេញលេញនូវបំណុលកកស្ទះគិតចាប់ពីឆ្នាំ២០០៧ មក[2] (៣) ការកែលម្អកិច្ចដំណើរការថវិកាជាមួយនឹងវដ្តនៃការរៀបចំថវិកា និង (៤) ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលបានក្លាយជាប្រព័ន្ធនៃការកត់ត្រាសម្រាប់រាជរដ្ឋាភិបាល គិតចាប់ពីខែមករា ឆ្នាំ២០១៧ មក ដើម្បីទ្រទ្រង់ដល់ការទូទាត់បានទាន់ពេលវេលា និងធានានូវសុក្រឹតភាពនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

លទ្ធផលនៃការប្រមូលចំណូល បានផ្តល់លទ្ធភាពបន្ថែមសម្រាប់ទ្រទ្រង់ដល់សកម្មភាពកែទម្រង់គន្លឹះៗមួយចំនួន ដែលរួមមាន (១) វិធានការសារពើពន្ធដោយប្រើប្រាស់ធនធាន២ ភាគរយនៃផ.ស.ស. ដើម្បីទប់ស្កាត់ឥទ្ធិពលអវិជ្ជមានពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩ ទៅលើជនងាយរងគ្រោះ ជាពិសេស កសិករ និងកម្មកររោងចក្រ (២) ការបង្កើនថវិកាសម្រាប់វិស័យសង្គមកិច្ច (៣) ការបង្កើនប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការសាធារណៈក្រោមកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ។

ជាមួយនឹងសមិទ្ធផលទាំងនេះ ក៏នៅមានបញ្ហាប្រឈមជាច្រើន ដែលតម្រូវឱ្យមានការពង្រឹងបន្ថែមលើការផ្សារភ្ជាប់រវាងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់សេវាសាធារណៈ ដែលបានកំណត់ក្នុងឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## បញ្ហាប្រឈម

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ មានកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីតួអង្គពាក់ព័ន្ធមកពីគ្រប់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍។ តាមរយៈកិច្ចប្រជុំនេះ បានបង្ហាញឱ្យឃើញអំពីវឌ្ឍនភាពល្អប្រសើរនៃកម្មវិធីកែទម្រង់។ ប៉ុន្តែ ក៏នៅមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ ដើម្បីធានាទំនើបភាវូបនីយកម្ម និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា។ បញ្ហាប្រឈមគន្លឹះៗមួយចំនួនមានដូចខាងក្រោម÷

*លំហូរធនធានទៅអង្គភាពផ្តល់សេវាសាធារណៈនៅមានភាពយឺតយ៉ាវ។* ប្រតិបត្តិការភាគច្រើននៅមានលក្ខណៈប្រមូលផ្តុំទៅតាមមុខងារ។ អង្គភាពនីមួយៗ ផ្តោតលើជំនាញជាក់លាក់ហើយបំពេញតែការងារផ្នែកនោះនៅក្នុងប្រតិបត្តិការងារដែលមានលក្ខណៈវែង មុននឹងសេវាត្រូវបានអនុម័ត និងផ្តល់ដល់អ្នកទទួល។ ប្រតិបត្តិការដែលវែង ទាមទារនូវប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលរវាងក្រសួង-ស្ថាប័ន និងរវាងអង្គភាព នៃក្រសួង-ស្ថាប័ននីមួយៗ ដែលជាក់ស្តែងប្រើប្រាស់ពេលវេលាច្រើន និងមិនមានគុណភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាពលរដ្ឋបានទាន់ពេលវេ-

[2] និយមន័យនៃបំណុលកកស្ទះ សំដៅដល់ចំណាយទាំងឡាយណាដែលមិនទាន់បានទូទាត់លើសពី៦០ថ្ងៃគិតចាប់ពីថ្ងៃដែលសំណើទូទាត់ត្រូវបានដាក់ជូនអគ្គនាយកដ្ឋានរតនាគារជាតិ

# ប្រសិទ្ធភាពនៃការកែលម្អវដ្តថវិកា

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ត្រូវបានផ្តួចផ្តើមរៀបចំ និងដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលដៅកែប្រែប្រព័ន្ធថវិកាជាតិពីការផ្តោតលើធាតុចូល និងមធ្យោបាយ ទៅជាការផ្តោតលើធាតុចេញ និងវិមធ្យោបាយ តាមរយៈការអនុវត្តជាជំហានៗ និងជាដំណាក់កាលៗ។*

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការកែទម្រង់រយៈពេលវែង ជាមួយនឹងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាច្បាស់លាស់ ដែលបានកំណត់ក្នុងឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលបានឆ្លុះបញ្ចាំងកាន់តែច្បាស់លាស់នៃប្រព័ន្ធថវិកាជាតិឆ្ពោះទៅរកថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម។

ជាការពិត, ចាប់តាំងពីការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់នេះមក មានសមិទ្ធផលជាច្រើនបានលេចជារូបរាងឡើងដែលបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដើរតួនាទីជាសេនាធិការក្នុងការផ្តល់សេវាជូនក្រសួង-ស្ថាប័ន ក្នុងកិច្ចដំណើរការថវិកាដែលមានកំណត់ទៅតាមវដ្តនៃថវិកា។

ជាក់ស្តែង ការរៀបចំ, ការអនុវត្ត និងការតាមដានត្រួតពិនិត្យថវិកា កាន់តែមានប្រសិទ្ធភាពល្អប្រសើរ។ តាមការកំណត់នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល ចំណាយ ការខ្ចី ការឱ្យខ្ចី និងការធានារបស់រដ្ឋដែលត្រូវបានអនុញ្ញាតដោយច្បាប់។ ការរៀបចំ ការអនុវត្ត និងការតាមដានវាយតម្លៃ ក៏ត្រូវបានគិតគូររៀបចំដូចខាងក្រោម÷

◈ **ការិយបរិច្ឆេទនៃកិច្ចដំណើរការរៀបចំថវិកា÷** គិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។

◈ **ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ÷** នៅសប្តាហ៍ទីមួយនៃខែមីនា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។ ជាក់ស្តែង ការរៀបចំនូវក្របខណ្ឌនេះកាន់តែមានភាពគ្រប់ជ្រុងជ្រោយ ដោយមានការចូលរួមពីសាធារណជនតាមរយៈវេទិកាសាធារណៈ ដែលបានចូលរួមចំណែកក្នុងការបង្កើន និងកែលម្អតម្លាភាពថវិកាកាន់តែប្រសើរបានមួយកម្រិតថែមទៀត។

◈ **ការរៀបចំថវិកា÷** នៅសប្តាហ៍ទីមួយនៃខែមេសា, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យមដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែឧសភា, រដ្ឋមន្ត្រីគ្រប់ក្រសួង, ប្រធានគ្រប់ស្ថាប័ន, ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅសប្តាហ៍ទីមួយនៃខែមិថុនា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារពាក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយផ្ញើជូនក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគម្រោងចំណូល-ចំណាយថវិកាលម្អិតរបស់ខ្លួន។ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា, គ្រប់ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូល-ចំណាយថវិកាលម្អិតរបស់ខ្លួន រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូល-ចំណាយថវិការបស់គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលបានស្នើឡើង។ ជាលទ្ធផល, ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំបានរៀបចំទាន់ពេលវេលា ជាមួយនឹងព័ត៌មានដែលត្រូវវិចខ្ចប់ កាន់តែឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងជាមួយនឹងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី។ រីឯការរៀបចំផែនការលទ្ធកម្ម ក៏ត្រូវបានកែលម្អ និងពង្រឹងលើភាពទាន់ពេលវេលា ដោយត្រូវផ្សារភ្ជាប់ជាមួយនឹងគម្រោងកញ្ចប់ថវិកាប្រចាំឆ្នាំផងដែរ។



*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការកែទម្រង់រយៈពេលវែង ជាមួយនឹងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាច្បាស់លាស់ដែលបានកំណត់ក្នុងឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។*



◈ **ការអនុម័តថវិកា÷** នៅក្នុងអំឡុងខែសីហាទាំងមូល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អញ្ជើញគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ មកពិភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល-ចំណាយថវិកាទាំងនោះឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូលឱ្យបានសមស្រប។ រីឯ នៅក្នុងអំឡុងខែកញ្ញាទាំងមូល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល-ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ

សម្រាប់ការគ្រប់គ្រង។ នៅសប្តាហ៍ទីមួយនៃខែតុលា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច, បន្ទាប់មកនៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះដាក់ជូនរដ្ឋសភាដើម្បីពិនិត្យអនុម័ត, និងជាចុងក្រោយ នៅសប្តាហ៍ទីមួយនៃខែធ្នូ, សេចក្តីព្រាងច្បាប់នេះ នឹងត្រូវដាក់ជូនព្រឹទ្ធសភាអនុម័តជាស្ថាពរឱ្យបានមុនថ្ងៃទី ២៥ ខែធ្នូ។ ជាក់ស្តែង តាមរយៈការពង្រឹងការអនុវត្តកម្មវិធីកែទម្រង់, ក្នុងដំណាក់កាលអនុម័តនេះ, ថវិកាដែលត្រូវបានគ្រោងឱ្យឆ្លើយតបនឹងគោលនយោបាយ កាន់តែត្រូវបានកែលម្អ ហើយធនធានដែលត្រូវបានបែងចែក និងអនុម័តកាន់តែមានប្រសិទ្ធភាពទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការរៀបចំបានទាន់ពេលវេលា។

*តាមការកំណត់នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូល-ចំណាយ ការខ្ចី ការឱ្យខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់។*

◈ ការអនុវត្តថវិកា÷ ក្រោយកញ្ចប់ថវិកាត្រូវបានអនុម័តជាស្ថាពរ, គ្រប់ក្រសួង-ស្ថាប័ន ក៏បានពង្រឹងការអនុវត្តថវិការបស់ខ្លួនទៅតាមនីតិវិធីការងារដែលបានចែងក្នុងលិខិតបទដ្ឋានគតិយុត្តនានាដែលបានកំណត់ ដែលប្រសិទ្ធភាពនៃការអនុវត្តនេះក៏បានឆ្លុះបង្ហាញតាមរយៈការពង្រឹងលើវិន័យថវិកាផងដែរ។

◈ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ÷ ជាមួយនឹងរបបប្រជុំជាទៀងទាត់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានធ្វើជាគម្រូក្នុងការដឹកនាំការប្រជុំតាមដានលើការអនុវត្តថវិកាកម្មវិធី ជាប្រចាំឆមាស និងឆ្នាំផងដែរ។

ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងលើការអនុវត្តប្រព័ន្ធថវិកាកម្ពុជាដែលបានកែលម្អគ្រប់ជំហាននីមួយៗនៃវដ្តថវិកា៕■




# ចំណាយថវិការដ្ឋតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន

*ការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងទៅតាមបរិការណ៍នៃតម្រូវការរបស់ប្រជាជន និងការរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ច។*

ការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើង ទៅតាមបរិការណ៍នៃតម្រូវការរបស់ប្រជាជន និងការរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ចជាតិ។ យោងតាមការចេញផ្សាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីថវិកាសង្ខេបសម្រាប់ឆ្នាំ២០១៦, ២០១៧ និង២០១៨, ចំណាយថវិការដ្ឋមានកំណើនចន្លោះពី ១៥,២% ទៅ ១៦,៥%។ ចំណាយថវិការដ្ឋត្រូវបានបែងចែកជាពីរធំៗ គឺចំណាយចរន្ត និងចំណាយមូលធន។ រដ្ឋទេយ្យបុរេប្រទាន គឺជានីតិវិធីចំណាយមួយក្នុងចំណោមនីតិវិធីជាច្រើនទៀតនៃការចំណាយចរន្ត ដោយមានលក្ខណៈជាការផ្តល់ថវិកាសម្រាប់ចំណាយមុន និងទូទាត់ជាក្រោយ។ រដ្ឋទេយ្យបុរេប្រទាន គឺជាចំណាយលើដំណើរការរដ្ឋបាល និងចំណាយដែលមានលក្ខណៈជាប្រចាំ ចាំបាច់ បន្ទាន់ និងមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់ធម្មតាបាន។ មុខសញ្ញាចំណាយតាមរដ្ឋទេយ្យបុរេប្រទានរួមមាន÷

- ◈ចំណាយចាំបាច់ជាប្រចាំ សម្រាប់ការងាររដ្ឋបាល (សម្ភារៈ, ការជួសជុល...)
- ◈ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់ និងពិសេស
- ◈ចំណាយសម្រាប់ប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស
- ◈ចំណាយសម្រាប់លាភការរបស់បុគ្គលិក
- ◈ចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា
- ◈ចំណាយសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពនៃថវិកាកម្មវិធី។

គ្រប់នីតិវិធីចំណាយទាំងអស់ ត្រូវគោរពទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន រួមមានច្បាប់, គោលការណ៍, បទបញ្ញត្តិ, ប្រកាស, សារាចរណែនាំ, គោលការណ៍ណែនាំ ជាដើម។ ហេតុនេះ នីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន ត្រូវគោរពទៅតាមលិខិតបទដ្ឋានគតិយុត្ត ដូចតទៅ÷

- ◈នីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានត្រូវបានធ្វើបច្ចុប្បន្នភាពដោយប្រកាស








ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ បានកែសម្រួលប្រការមួយចំនួននៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- សារាចរណែនាំលេខ ០១៨ សហវ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ០០៤ សហវ. ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ (ប្រកាស ១៩១១ សហវ, ៨៣៨ សហវ. ជាដើម)

*រជ្ជទេយ្យបុរេប្រទាន គឺជានីតិវិធីចំណាយមួយក្នុងចំណោមនីតិវិធីជាច្រើនទៀតនៃការចំណាយថវិកា ដោយមានលក្ខណៈជាការផ្តល់ថវិកាសម្រាប់ចំណាយមុន និងទូទាត់ជាក្រោយ។*

ដើម្បីអនុវត្តចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន, អង្គភាពថវិកាត្រូវរៀបចំតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងអាចមានរជ្ជទេយ្យករបុរេប្រទានរង មួយចំនួនជាជំនួយការតាមការចាំបាច់។

នីតិវិធីនៃការអនុវត្តចំណាយតាមថវិការដ្ឋតាមនីតិវិធីរជ្ជទេយ្យបុរេប្រទានត្រូវអនុវត្តទៅតាមដំណាក់កាលទាំង៣ គឺដើមឆ្នាំ, ក្នុងឆ្នាំ, និងចុងឆ្នាំ ដូចខាងក្រោម÷

### ដើមឆ្នាំ

ជំហានទី១÷ ការរៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ជាដំណាក់កាលនៃការរៀបចំកញ្ចប់រជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ដែលរៀបចំជា ២ ប្រភេទ គឺ÷ (១) តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និង (២) តាមចំណាត់ថ្នាក់កម្មវិធី។ ប្រព័ន្ធ FMIS នឹងត្រួតពិនិត្យឥណទាន (Budget Check) តាមចំណាត់ថ្នាក់សេដ្ឋកិច្ចផង (ដល់អនុគណនី) និងចំណាត់ថ្នាក់កម្មវិធីផង (ដល់ចង្កោមសកម្មភាព)។ តារាងឧបសម្ព័ន្ធនេះត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលឡើងវិញក្នុងឆ្នាំ តាមតម្រូវការចំណាយជាក់ស្តែង។

### ក្នុងឆ្នាំ

ជំហានទី២÷ ការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទានពីរតនាគារជាតិ ត្រូវបានធ្វើឡើងបន្ទាប់ពីតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានត្រូវបានអនុម័ត។ ចំនួនទឹកប្រាក់ដែលត្រូវដកនៅដើមឆ្នាំ គឺស្មើនឹងមួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាននៅក្នុងតារាងឧបសម្ព័ន្ធដែលបានអនុម័ត។ ក្នុងករណីដែលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានមិនអាចអនុម័តទាន់ពេលវេលា ចំនួនទឹកប្រាក់ដែលត្រូវដកនៅដើមឆ្នាំ គឺស្មើនឹងមួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាននៅក្នុងតារាងឧបសម្ព័ន្ធដែលបានអនុម័តនៅឆ្នាំចាស់។

ក្នុងឆ្នាំ ការដកសាច់ប្រាក់ពីរតនាគារជាតិត្រូវបានធ្វើឡើងបន្ទាប់ពីជំហានទី៤÷ ការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ ដើម្បីបំពេញបេឡារជ្ជទេយ្យបុរេប្រទានឡើងវិញ។ ចំនួនទឹកប្រាក់ដែលត្រូវដក គឺស្មើនឹងចំនួនទឹកប្រាក់ដែលបានស្នើសុំបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ និងត្រូវបានអនុម័ត។

ជំហានទី៣÷ ការចំណាយ និងប្រមូលសក្ខីបត្រចំណាយ ជាដំណាក់កាលដែលមានថវិកានៅក្នុងបេឡារជ្ជទេយ្យបុរេប្រទានសម្រាប់ធ្វើការចំណាយក្នុងដំណើរការគាំទ្រសកម្មភាពប្រចាំថ្ងៃរបស់អង្គភាពថវិកានីមួយៗ និងទៅតាមប្រភេទចំណាយ ដែលច្បាប់អនុញ្ញាតសម្រាប់ចំណាយរជ្ជទេយ្យបុរេប្រទាន។ រាល់ការចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន គឺត្រូវមានគោលការណ៍ចំណាយពីអាណាប័ក ឬពីអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ រាល់ការចំណាយត្រូវមានសក្ខីបត្រចំណាយគាំទ្រ ដើម្បីទុកជាឯកសារយោងសម្រាប់ទូទាត់ជាមួយរតនាគារជាតិ (គណនេយ្យករសាធារណៈ)។ ទឹកប្រាក់សម្រាប់មួយប័ណ្ណចំណាយ មិនលើស ៥ លានរៀល ហើយត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង ពេលវេលា និងសមាសភាពនៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវេះការទូទាត់ត្រង់ ឬការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ លើកលែងតែចំណាយមួយចំនួន ដែលត្រូវទូទាត់តាមជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ។

ជំហានទី៤÷ ការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ ជាដំណាក់កាលក្រោយពីចំណាយថវិការជ្ជទេយ្យបុរេប្រទាន ពោលគឺបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ដើម្បីបំពេញបេឡាសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន និងជម្រះបុរេប្រទានពីរតនាគារ (នាពេលដំណាច់ឆ្នាំ)។ រជ្ជទេយ្យករបុរេប្រទានគួរគិតគូររៀបចំបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ទៅតាមចំនួនទឹកប្រាក់ចំណាយជាក់ស្តែង ដោយពុំចាំបាច់រង់ចាំដល់ចំណាយអស់ចំនួនទឹកប្រាក់ដែលបានបើកពីរតនាគារជាតិនោះទេ ពោលគឺ រជ្ជទេយ្យករបុរេប្រទាន អាចមានថវិកាចំណាយលើប្រតិបត្តិការប្រចាំ ដោយមានការរាំងស្ទះឡើយ។






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

ប្រកាស
ស្តីពី
នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន
សម្រាប់រដ្ឋបាលថ្នាក់ជាតិ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

វិក្កយបត្រ ឬសក្ខីបត្រចំណាយ ដែលចុះកាលបរិច្ឆេទមុនពេលមានប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន ៣០ ថ្ងៃ ត្រូវបានអនុញ្ញាតឱ្យទូទាត់បាន ប៉ុន្តែប័ណ្ណចំណាយត្រូវចុះកាលបរិច្ឆេទក្រោយពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន។ ក្នុងករណីលើស ៣០ ថ្ងៃ ត្រូវស្នើសុំគោលការណ៍ដោយឡែកពីអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ។ ដើម្បីទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន, រជ្ជទេយ្យករបុរេប្រទាន ត្រូវរៀបចំឯកសារមួយចំនួនដូចខាងក្រោម÷

- អាណត្តិនិយ័តកម្ម, ដីកាអមបញ្ចេញអាណត្តិ និងដីកាអមលិខិតយុត្តិការ
- សលាកប័ត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ
- លិខិតស្នើសុំទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទាន
- របាយការណ៍ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន (តាមដានជាប្រចាំ)
- តារាងសម្រង់ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន (តាមប័ណ្ណចំណាយ និងថ្ងៃខែ, មាតិកាចំណាយថវិកា, បរិយាយកម្មវត្ថុចំណាយ, មានទឹកប្រាក់សរុបស្មើនឹងចំនួនទឹកប្រាក់នៃអាណត្តិនិយ័តកម្មដែលស្នើសុំទូទាត់...)
- ប័ណ្ណចំណាយ, វិក្កយបត្រ និងសក្ខីបត្រចំណាយ, ប័ណ្ណបើកសាច់ប្រាក់ ព្រមទាំងលិខិតយុត្តិការចំណាយមួយចំនួនផ្សេងទៀត ទៅតាមមុខសញ្ញាចំណាយ (បេសកកម្ម...)

### ចុងឆ្នាំ

ជំហានទី៥÷ ការទូទាត់សាច់ប្រាក់រជ្ជទេយ្យបុរេប្រទានដែលសល់ចុងឆ្នាំ ជាដំណាក់កាលចុងឆ្នាំនៃការបិទបញ្ចប់ចំណាយរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំនីមួយៗ។ ការទូទាត់ចុងឆ្នាំ ត្រូវបានធ្វើឡើងជាពីរប្រភេទ គឺ ១) បោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ជម្រះបុរេប្រទានពីរតនាគារជាតិ និង ២) ការបង់ប្រាក់រជ្ជទេយ្យបុរេប្រទាន ដែលនៅសល់ចូលគណនីរបស់រជ្ជទេយ្យករបុរេប្រទាននៅរតនាគារជាតិ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី។

*គ្រប់នីតិវិធីចំណាយទាំងអស់ ត្រូវគោរពទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន រួមមាន÷ច្បាប់ គោលការណ៍ បទបញ្ញត្តិ ប្រកាស សារាចរណែនាំ គោលការណ៍ណែនាំជាដើម។*

ជារួម, ការចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីបានរួមចំណែកគាំទ្រសមិទ្ធកម្មនៃគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង-ស្ថាប័នថវិកាកម្មវិធី ជាពិសេស បង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តចំណាយ ប្រកបដោយភាពទាន់ពេល, តម្លាភាព, គណនេយ្យភាព, និងការទទួលខុសត្រូវខ្ពស់ដែលអាចផ្តល់លទ្ធភាពងាយស្រួលដល់ការអនុវត្តចំណាយដំណើការរដ្ឋបាល និងសកម្មភាពនៃថវិកាកម្មវិធី ស្របតាមសកម្មភាព និងតម្រូវការចាំបាច់របស់ក្រសួង-ស្ថាប័នថវិកាកម្មវិធី៕■

# ការរៀបចំយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣

*ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យឆ្នាំ២០៣០ ប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជាមូលដ្ឋានមានចរិតជាយុទ្ធសាស្ត្រសម្រាប់ការរៀបចំផែនការ និងគោលនយោបាយជាក់លាក់តាមវិស័យទាំងសង្គម និងសេដ្ឋកិច្ច ឱ្យមានភាពស៊ីចង្វាក់ និងប្រទាក់ក្រឡា ដើម្បីធានាបាននូវការអភិវឌ្ឍទៅមុខប្រកបដោយជោគជ័យខ្ពស់។*

ឈរលើមូលដ្ឋាននេះ និងសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃសង្គម-សេដ្ឋកិច្ចជាតិ និងតំបន់ ព្រមទាំងជវភាពពាណិជ្ជកម្ម ធុរៈកិច្ច ឥរិយាបទអ្នកប្រើប្រាស់ សុខភាព និងបរិស្ថាន ដែលនឹងដាក់ឱ្យអនុវត្តនាដើមឆ្នាំ២០១៩ នេះ។ យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ នឹងក្លាយជាឧបករណ៍គោលនយោបាយមួយយ៉ាងសំខាន់ ក្នុងការគៀរគរចំណូលរដ្ឋប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិខ្ពស់ តាមរយៈការកំណត់នូវទិសដៅជាក់លាក់ និងវិធានការមុតស្រួចនានាសម្រាប់អនុវត្តក្នុងរយៈពេលមធ្យមខាងមុខ។

> *យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ផ្តោតលើការធ្វើទំនើបភាវូបនីយកម្មទាំងគោលនយោបាយសារពើពន្ធ និងរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របនឹងការវិវឌ្ឍនៃបរិបទសេដ្ឋកិច្ច-សង្គម ដើម្បីធានាចីរភាពចំណូលរដ្ឋ និងឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម*




យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ មានចក្ខុវិស័យប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើប ដើម្បីជំរុញការប្រមូលចំណូលជាតិឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ និងឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០-៣០។

ដើម្បីសម្រេចបានចក្ខុវិស័យនេះ យុទ្ធសាស្ត្រនេះមានគោលបំណងធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធប្រមូលចំណូល ទាំងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ឱ្យស្របតាមការវិវឌ្ឍនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជាតិ តាមរយៈការរៀបចំឡើងវិញនូវប្រភេទពន្ធមួយចំនួន ឱ្យមានភាពល្អប្រសើរ និងកែសម្រួលរដ្ឋបាលចំណូលស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ពិសេសស្របតាមនិន្នាការសេដ្ឋកិច្ច-សង្គមសម័យទំនើប ដើម្បីធានានូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ចីរភាព និងបរិយាប័ន្ន។

យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំដោយផ្អែកលើគោលការណ៍បួនគឺ÷ ១) ធានាចីរភាពកំណើនសេដ្ឋកិច្ច, ២) រក្សាបាននូវចីរភាពចំណូលក្នុងកម្រិតឧត្តមានុពល (optimal level), ៣) ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយពន្ធ និងការប្រមូលចំណូល, និង ៤) ធានានូវសមធម៌រវាងអ្នកជាប់ពន្ធ ដើម្បីបង្កើនសុខុមាលភាព និងបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប។




យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ផ្តោតលើការធ្វើទំនើបភាវូបនីយកម្មទាំងគោលនយោបាយសារពើពន្ធ និងរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របនឹងការវិវឌ្ឍនៃបរិបទសេដ្ឋកិច្ច-សង្គម ដើម្បីធានាចីរភាពចំណូលរដ្ឋ និងឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលចំណូលនឹងផ្តោតលើចំណុចគន្លឹះចំនួន៥÷

- ការរៀបចំឡើងវិញនូវដំណើរការប្រតិបត្តិការ (Re-Engineering Business Processes)÷ ការធ្វើប្រតិភូកម្មការងារ និងការសម្រេចចិត្ត និងការផ្លាស់ប្តូរការគ្រប់គ្រងរបស់អង្គភាព។ល។
- គុណភាពសេវាអ្នកជាប់ពន្ធ÷ Web Portal, ជំនួយការសិប្បនិម្មិត (vitual assistant), ការគ្រប់គ្រងទំនាក់ទំនងអតិថិជន, ការិយាល័យផ្តល់សេវា, ការដាក់លិខិតប្រកាសតាមប្រព័ន្ធអេឡិចត្រូនិក, ការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជាដើម។
- សមាហរណកម្មប្រព័ន្ធរដ្ឋបាលសារពើពន្ធ (Integrated Tax System)÷ ការគ្រប់គ្រងលំហូរការងារ, ការគ្រប់គ្រងនីតិវិធីអាជីវកម្ម, ការគ្រប់គ្រងឯកសារ, ការធ្វើរបាយការណ៍, គណនេយ្យ, បេឡា, និងលិខិតទំនាក់ទំនង ជាដើម។
- ការវិភាគដែលប្រើទិន្នន័យជាមូលដ្ឋាន÷ ការវិភាគទិន្នន័យពាណិជ្ជកម្ម (business intelligence), ឃ្លាំងផ្ទុកទិន្នន័យ។ល។
- ហេដ្ឋារចនាសម្ព័ន្ធ÷ មជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ, ការស្តារឡើងវិញពីគ្រោះមហន្តរាយ, ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ, ការបង្កើនសុវត្ថិភាព, កន្លែងការងារ ជាដើម។■

## លក្ខខណ្ឌគន្លឹះនៃការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលចំណូលពន្ធ



# អ្វីជាសូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicator)?

*និយមន័យសម្រាប់សូចនាករត្រូវបានកំណត់ផ្សេងៗគ្នាអាស្រ័យលើបរិបទនៃស្ថានភាពនីមួយៗ។ តាមរយៈបទពិសោធនៃការរៀបចំ និងអនុវត្តនូវសូចនាករសមិទ្ធកម្មសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកន្លងមក សូចនាករត្រូវបានផ្តល់និយមន័យសាមញ្ញ ជាឧបករណ៍សម្រាប់វាស់វែងសមិទ្ធកម្ម/លទ្ធផលដែលសម្រេចបានធៀបនឹងគោលដៅដែលបានកំណត់។*

ប្រសិនបើមិនកំណត់សូចនាករសមិទ្ធកម្មទេ, ស្ថាប័នមួយនឹងពិបាកក្នុងការវាស់វែងនូវលទ្ធភាពសម្រេចបាននូវចក្ខុវិស័យ, លទ្ធផលជាបំណងប្រាថ្នាចង់បាន ឬការប្រកួតប្រជែង។ល។ អាស្រ័យហេតុនេះ, សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយទាំងក្នុងវិស័យសាធារណៈ, កិច្ចសហប្រតិបត្តិការជាដៃគូ, អង្គការមិនមែនរដ្ឋាភិបាល, និងវិស័យឯកជន។ ក្នុងន័យនេះ, ការប្រើប្រាស់ KPI នឹងផ្តល់នូវតម្លៃបន្ថែមសម្រាប់ស្ថាប័ន រួមមានការកំណត់យុទ្ធសាស្ត្រមានភាពច្បាស់លាស់, យុទ្ធសាស្ត្រផ្តោតលើភាពជាក់លាក់, និងយុទ្ធសាស្ត្រមានបង្ហាញនូវចំណុចដែលត្រូវកែលម្អ។

ជាទូទៅ សូចនាករសមិទ្ធកម្មត្រូវបានកំណត់ដោយស្របតាមគោលការណ៍ SMART រួមមាន Specific (ច្បាស់លាស់), Measurable (អាចវាស់វែងបាន), Attainable (អាចសម្រេចបាន), Relevant (សារៈសំខាន់ និងភាពពាក់ព័ន្ធនៃយុទ្ធសាស្ត្រ), និង Timeframe (មានការកំណត់ពេលវេលា)។ ទន្ទឹមនេះ ដើម្បីរៀបចំ និងជ្រើសរើស KPI ឱ្យបានត្រឹមត្រូវ, អ្នករៀបចំត្រូវសិក្សាអំពីកត្តាខាងក្នុង (យុទ្ធសាស្ត្រ, ថ្នាក់ដឹកនាំ, មន្ត្រី/បុគ្គលិក, ការរៀបចំ និងប្រព្រឹត្តទៅរបស់ស្ថាប័ន, របាយការណ៍ហិរញ្ញវត្ថុ, របាយការណ៍សមិទ្ធកម្ម និងកិច្ចប្រតិបត្តិការ) និងកត្តាខាងក្រៅ (ដៃគូប្រកួតប្រជែង, អតិថិជន, បរិបទសេដ្ឋកិច្ច និងនយោបាយ) ឱ្យបានច្បាស់លាស់ជាមុនសិន។ ជំហានបន្ទាប់, អ្នករៀបចំត្រូវរៀបចំតាមវិធីសាស្ត្រក្របខណ្ឌតក្កកម្មវិធីដោយក្នុងនោះរួមមាន ធាតុចូល, លទ្ធផលក្នុងឆ្នាំ, លទ្ធផលចុងក្រោយ និងការជះឥទ្ធិពលជាវិជ្ជមាន។




ខាងក្រោមបង្ហាញអំពីការប្រើប្រាស់ KPI ក្នុងទម្រង់ផ្សេងៗគ្នា អាស្រ័យលើបរិបទនៃស្ថាប័ននីមួយៗ។

- គ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញដែលប្រើប្រាស់ទម្រង់សម្រាប់រៀបចំក្របខណ្ឌលទ្ធផលដូចខាងក្រោម÷

១. ទម្រង់រៀបចំក្របខណ្ឌលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល

| ឈ្មោះ អនុកម្មវិធី/ ចង្កោមសកម្មភាព | សូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅ | | | |
|---|---|---|---|---|
| | សូចនាករ | ឆ្នាំ២០១៧ (អនុវត្ត) | ឆ្នាំ២០១៨ (បច្ចុប្បន្ន) | ឆ្នាំ២០១៩ (គ្រោង) |
| កម្មវិធីទី១: កិច្ចការច្បាប់ | | | | |
| អនុកម្មវិធីទី១.១: សេវាអយ្យការ និងព្រហ្មទណ្ឌ | | | | |
| អនុកម្មវិធីទី១.២: សេវារដ្ឋប្បវេណី | | | | |
| អនុកម្មវិធីទី១.៣: សេវាអភិវឌ្ឍលើវិស័យយុត្តិធម៌ | | | | |

២. ទម្រង់រៀបចំក្របខណ្ឌលទ្ធផលនៃការរៀបចំថវិកាប្រចាំឆ្នាំ

ការគ្រប់គ្រងឆ្នាំ......

សូចនាករ និងគោលដៅសូចនាករនៃថវិកាកម្មវិធី

ក្រសួង ស្ថាប័ន.......

| កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព | ឥណទានថវិកា (លានរៀល) | លទ្ធផលក្នុងឆ្នាំ (Output Indicator) (មិនឱ្យលើសពី៣ សម្រាប់កម្រិតកម្មវិធី) | | សូចនាករលទ្ធផលចុងក្រោយ (Outcome Indicator) (មិនឱ្យលើសពី២ សម្រាប់កម្រិតកម្មវិធី) |
|---|---|---|---|---|
| | | សូចនាករលទ្ធផលក្នុងឆ្នាំ | គោលដៅ | |
| ១. កម្មវិធីទី១:........................ | | | | |
| ១.១. អនុកម្មវិធីទី១:................ | | | | |
| ១.១.១ ច.ស.ទី១:................ | | | | |
| ១.១.២ ច.ស.ទី២:................ | | | | |
| ........................................ | | | | |
| ១.២. អនុកម្មវិធីទី២:................ | | | | |
| ........................................ | | | | |
| ២. កម្មវិធីទី២:........................ | | | | |
| ២.១. អនុកម្មវិធីទី១:................ | | | | |
| ២.១.១ ច.ស.ទី១:................ | | | | |
| ២.១.២ ច.ស.ទី២:................ | | | | |
| ........................................ | | | | |
| ២.២. អនុកម្មវិធីទី២:................ | | | | |
| ........................................ | | | | |
| ... កម្មវិធីទី...:........................ | | | | |
| ...... អនុកម្មវិធីទី១:................ | | | | |
| ...... ច.ស.ទី១:................ | | | | |
| ........................................ | | | | |
| ...... អនុកម្មវិធីទី២:................ | | | | |
| ........................................ | | | | |

- សម្រាប់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សូចនាករសមិទ្ធកម្មត្រូវបានប្រើប្រាស់ក្នុងក្របខណ្ឌលទ្ធផលក្នុងទម្រង់ផ្សេងៗ ពីគ្នាអាស្រ័យលើទម្រង់របស់ដៃគូអភិវឌ្ឍន៍។

១. ក្របខណ្ឌលទ្ធផលរបស់សហភាពអឺរ៉ុប

| **Specific Condition: Indicator 7** | Domestic revenue mobilisation strengthening |
|---|---|
| Targets | 2019: Annual increase of total current revenue collection as percentage of GDP.<br>2020: Annual increase of total current revenue collection as percentage of GDP. |
| Description | Cambodia has implemented a very successful Domestic Revenue Mobilization Strategy covering the period 2014-2018. During this time, the country has increased domestic revenue by 0.9% of the GDP annually. MEF is currently working to complete a new Domestic Revenue Mobilization Strategy 2019-2023. |
| Objective | Increased collection of domestic revenue to finance national reforms and increased predictability in budget execution |
| Responsible agency | MEF: General Department of Policy (GDP), General Department of Taxation (GDT), General Department of Customs and Excise (GDCE), General Department of State Property and Non-Tax revenue (GDSPNT), General Department of Financial Industry (GDFI), and related Agencies |
| Period of assessment | 2019 and 2020 |
| Sources | TOEF for domestic revenue (General Government)<br>GDP estimation in Circular on Budget Strategic Plan. If the actual GDP is available by NIS of MoP, calculation is based on official actual data. |
| Method of calculation | Indicators assess the increase of total current revenue to GDP (total current revenue/GDP-Production at current price)*100 |
| Baseline | 2017=20.1% of GDP |

## ២. ក្របខណ្ឌលទ្ធផលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

| Policy Actions | Key Performance Indicators July 2016- June 2019 | Medium term directions and expected results (Post Program Partnership Framework) |
|---|---|---|
| **Output 1: Policy and regulatory framework for expenditure and revenue management strengthened.** | | |
| 1. A. Improved policy-base of national budget. | 1. Amendment to Law on State Budget System (2008) prepared to institutionalize PFM reforms including provision for the National Assembly to pass the annual budget in a program budgeting format (2020). | Strengthened policy and regulatory framework for budget-policy linkages. Public Expenditure and Financial Accountability (PEFA) performance indicators (PIs) will improve from (2015 levels) as follows: c PI (2) Composition of expenditure outcomes compared to budget (D+). PI (3) Aggregate revenue outcome compared to budget (A). PI (12) Multi-year perspective in fiscal plans, expenditure |
| | 2. CAP for stage 3 of the PFMRP implemented and progress reported annually | |
| | 3. Government-wide MTEF for 2018-2020 adopted (2017). Significant net positive resource allocation impacts are estimated for successful movement to MTBF, in line with international experience. | |
| | 4. MTRMS implemented with revenues (excluding grants) growing over the medium term on average at 0.5 percentage point of GDP per year or from a total of 13.5% of GDP in fiscal rear (FY) 2013 to 16.0% of GDP in FY 2018 (2013 baseline: 13.5% of GDP). | |



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| Policy Actions | Key Performance Indicators July 2016- June 2019 | Medium term directions and expected results (Post Program Partnership Framework) |
|---|---|---|
| 1. B. Improved expenditure management and accountability systems. | 5. Comprehensive financial management manual for government budgeting approved, and used for budget preparation, execution, and financial and performance reporting. Important for consolidating guidelines in one place for training/guidance of line ministries. | plans budgets (C+). |
| | 6. Stage 1 of FMIS fully operationalized in MEF and 25 provincial treasuries, including with International Public Sector Accounting Standards (IPSAS)- cash basis financial statements; and stage 2 implementation started for expanding system functionality and coverage to LMs. Estimated to provide major benefits in operating efficiencies; corruption reduction and information to support changes to resource allocation (in line with international experience). | |
| | 7. Government-wide internal audit manual based on international internal auditing standards, including policy on principles for internal control of information and communication technology (ICT) approved. | |
| 1.C.Strengthened public debt management. | 8. Updated Public Debt Management Strategy 2015-2018 implemented, including approvals of (i) guidelines on government guarantees, including guarantees on public private partnership projects (PPPs); and (ii) Standard Operating Procedures. Better control of contingent liabilities will provide financial efficiencies; while a framework for PPPs will enhance investment and growth. | |
| | 9. DMFAS implemented with reports on all loans and grants produced monthly. | |
| | 10. Publication of subsequent six- monthly public debt statistical bulletins. | |

## ៣. ក្របខណ្ឌលទ្ធផលរបស់យូនីសេហ្វ

| Planned Description | Timeframe 2018 | | | | Geography Coverage | Implementing Partner(s) | Source of Funds | 2018 | |
|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | | | | Planned | Funded |
| **Key Result 4.1.2: MEF with enhanced capacity to provide technical support to social ministries in formulation, execution and in M&E of PB** | | | | | | | | | |
| 4.1.2.1: Provide technical support to GDB (BFD) to improve training materials on BSP and PB and training/coaching to BFD team | X | | | | National level | MEF-GDB (BFD) | RR | 0 | 0 |
| 4.1.2.2: Capacity development of GDB/BFD in result based budgeting, result based management and/or result based monitoring and | X | X | | | National level | MEF-GDB (BFD) | GS160029 and RR | 32,000 | 32,000 |

| Planned Description | Timeframe 2018 | | | | Geography Coverage | Implementing Partner(s) | Source of Funds | 2018 | |
|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | | | | Planned | Funded |
| **Key Result 4.1.2: MEF with enhanced capacity to provide technical support to social ministries in formulation, execution and in M&E of PB** | | | | | | | | | |
| evaluation to prepare for implementation of Budget System Reform Strategy 2018-2025 | | | | | | | | | |
| 4.1.2.3: TA to MEF GDB on assessment of PB capacity gap and M&E system of MEF and key social ministries, development of capacity development plan, consultation and implementation of action plan | X | X | X | | National and Provincial level | UNICEF (TA) and MEF-GDB (BFD) | GS160029 (40,628) & RR (19,372) | 65,000 | 60,000 |
| 4.1.2.4: Technical support to GDB/BFD to improve design and dissemination of budget documents (budget in brief) | | | X | X | National level | UNICEF (TA) and MEF-GDB (BFD) | RR | 10,000 | 5,000 |
| 4.1.2.5: Develop concept note on PB M&E to prepare for development of guideline for PB M&E and implementation of Budget System Reform Strategy 2018-2025 | | X | X | X | National level | UNICEF, MEF-GDB (BFD) | RR | 0 | 0 |
| 4.1.2.6: Support MEF GDB (FAD) in developing PB execution training manual for social ministries and/or developing capacity in result based management, result based budgeting and result based M&E | | X | X | X | National and provincial level | MEF-GDB (FAD) | RR | 0 | 0 |
| 4.1.2.7: Support GDNT at central level to develop training materials and to provide ongoing support and monitoring to provincial treasury in | | X | X | X | National, provincial and commune/sangkat level | MEF-GDNT | RR | 3,000 | 3,000 |





| Planned Description | Timeframe 2018 | | | | Geography Coverage | Implementing Partner(s) | Source of Funds | 2018 | |
|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | | | | Planned | Funded |
| **Key Result 4.1.2: MEF with enhanced capacity to provide technical support to social ministries in formulation, execution and in M&E of PB** | | | | | | | | | |
| promoting commune/sangkat social service expenditure | | | | | | | | | |
| 4.1.2.8: Collaborate with MEF GDNT to support provincial treasury to provide ongoing technical support and coaching to communes/sangkat on budget formulation and execution for social service activities in target provinces (Battambang, Siem Reap, Kracheh, Ratanakiri, Kandal, Phnom Penh and Sihanoukville) | | | | | Provincial level | MEF-GDNT | RR | 9,000 | 8,400 |
| 4.1.2.9: Technical support to GDSNAF for developing assessment tools and staff capacity on result based PB and BSP, improving training materials (e.g. slide presentation and exercise materials), and developing performance report template focusing on social service activities for children at provincial and capital level | | | | | National level | UNICEF and MEF-GDSNAF | RR | 0 | 0 |
| 4.1.2.10: Collaborate with MEF GDSNAF and GDNT, MoI, NCDDS and relevant ministries in developing provincial/capital budget formulation and execution guideline and capacity for social service activities for children | | | | | National level and provincial level | MEF-GDSNAF | RR | 7,500 | 7,500 |

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| Planned Description | Timeframe 2018 | | | | Geography Coverage | Implementing Partner(s) | Source of Funds | 2018 | |
|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | | | | Planned | Funded |
| **Key Result 4.1.2: MEF with enhanced capacity to provide technical support to social ministries in formulation, execution and in M&E of PB** | | | | | | | | | |
| 4.1.2.11: Collaborate with MEF (GDSNAF) to monitor and promote social service expenditure at commune in the targeted provinces. | | | | | National, provincial and commune/sangkat level | MEF-GDSNAF | RR | 3,000 | 3,000 |
| **Sub-Total** | | | | | | | | ***129,500*** | ***118,900*** |

៤. ក្របខណ្ឌលទ្ធផលរបស់ធនាគារពិភពលោក

**Project Development Objectives**

PDO Statement:

The project development objective is to enhance public financial management by strengthening: (a) revenue mobilization and (b) budget execution processes through the implementation of the Financial Management Information System (FMIS). Progress against the principal objective will be measured by the contribution made to the PFMRP's Key Performance Indictors and Targets set forth under the Stage Two of the PFMRP.

| No | Indicators | Unit of Measure | Baseline | Accumulative Target Value | | Data Source/ Methodology | Responsibility for data collection |
|---|---|---|---|---|---|---|---|
| | | | | 2016 | End 2017 | | |
| 1 | Improved timeliness to locate financial data and report | Time spent to locate financial data and report | It took up to two days to locate specific data | Less than 30 mn | Less than 30 mn | GDNT's report | GDNT, FMWG, GDB, GDSNAF, related agencies |
| 2 | Improved timeliness in the payment processing at GDNT | Time spent on processing payment at GDNT | Payment process could take between 15 to 30 days in 2013 | 10-15 working days | 10-15 working days | GDNT's report: Payment Process Duration Report | GDNT, related agencies |
| 3 | More timely closure of financial accounts at the end of the fiscal year | # of months after each fiscal year | 9 to 10 months delay in financial account closure | 3 - 4 months | 3 – 4 months | GDNT's report | GDNT, GDB, GDSNAF, related agencies |

# ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

*ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Finance Accountability-PEFA) គឺជាឧបករណ៍វាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយប្រទេសប្រមាណ ១៥០។*

ក្របខណ្ឌ PEFA ត្រូវបានបែងចែកជាពីររួមមាន PEFA សម្រាប់ថ្នាក់ជាតិ និង PEFA ថ្នាក់ក្រោមជាតិ។ សម្រាប់បទពិសោធនៃការវាយតម្លៃ PEFA នៅកម្ពុជា សម្រាប់ថ្នាក់ជាតិ ត្រូវប្រើប្រាស់ចំនួន ២ លើក ដោយលើកទីមួយ ធ្វើឡើងក្នុងឆ្នាំ២០១០ ដែលប្រើប្រាស់ទិន្នន័យឆ្នាំ២០០៦, ២០០៧, និង២០០៨ ហើយលើកទីពីរ នៅឆ្នាំ២០១៥ ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១១, ២០១២ និង២០១៣។ ទោះបីជាយ៉ាងនេះក្តី, សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅកម្ពុជា គឺពុំទាន់បានធ្វើការវាយតម្លៃនៅឡើយ ដែលគ្រោងធ្វើការវាយតម្លៃនៅឆ្នាំ២០១៩ នេះ។

រចនាសម្ព័ន្ធ PEFA ត្រូវបានបែងចែកលទ្ធផលចុងក្រោយចំនួន៣ (វិន័យថវិកា, យុទ្ធសាស្ត្រវិភាជន៍ថវិកា និងប្រសិទ្ធភាពការផ្តល់សេវាសាធារណៈ), សសរស្តម្ភចំនួន៧, សូចនាករសមិទ្ធកម្មចំនួន៣១ និងសមាសធាតុចំនួន៩៤ សម្រាប់ក្របខណ្ឌរដ្ឋបាលថ្នាក់ជាតិ។ រីឯ សម្រាប់ក្របខណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន PEFA គឺដូចនឹងសូចនាករថ្នាក់ជាតិដែរ ប៉ុន្តែបន្ថែមមួយសូចនាករ "ភាពប៉ាន់ប្រមាណការផ្ទេរធនធានពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិ" និងសមាសធាតុចំនួន៣ រួមមាន ១) គម្លាតថវិកាប្រចាំឆ្នាំរវាងការផ្ទេរថវិកាសរុបជាក់ស្តែងពីច្បាប់ថវិកា ពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ, ២) គម្លាតប្រចាំឆ្នាំរវាងការផ្ទេរធនធានហិរញ្ញវត្ថុជាក់ស្តែង និងធនធានហិរញ្ញវត្ថុក្នុងច្បាប់ថវិកា និង ៣) ភាពទាន់ពេលវេលានៃការផ្ទេរថវិកាក្នុងឆ្នាំពីថ្នាក់ជាតិ៕■

ដ្យាក្រាម÷ ភាពប្រទាក់ក្រឡាគ្នានៃសសរស្តម្ភទាំង៧



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ក្របខណ្ឌសូចនាករទាំង៣១ និងសមាសធាតុទាំង៩៧ មានលម្អិតដូចតទៅ៖*

| សសរស្តម្ភ | សូចនាករ | សមាសធាតុ |
|---|---|---|
| I. ភាពជឿទុកចិត្តនៃថវិកា | PI-១. លទ្ធផលនៃការអនុវត្តចំណាយសរុប | ១.១. លទ្ធផលនៃការអនុវត្តចំណាយសរុប |
| | PI-២. លទ្ធផលនៃសមាសធាតុចំណាយសរុប | ២.១. លទ្ធផលសមាសភាគចំណាយតាមចំណាត់ថ្នាក់មុខងារ |
| | | ២.២. លទ្ធផលសមាសភាគចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ច |
| | | ២.៣. ការចំណាយដកចេញពីគណនីក្នុងការគ្រោងទុក |
| | PI-៣. លទ្ធផលនៃការប្រមូលចំណូល | ៣.១. លទ្ធផលការប្រមូលចំណូលសរុប |
| | | ៣.២. លទ្ធផលសមាសភាគប្រមូលចំណូល |
| II. តម្លាភាពហិរញ្ញវត្ថុសាធារណៈ | PI-៤. ចំណាត់ថ្នាក់ថវិកា | ៤.១. ចំណាត់ថ្នាក់ថវិកា |
| | PI-៥. ឯកសារថវិកា | ៥.១. ឯកសារថវិកា |
| | PI-៦. ប្រតិបត្តិការថវិកានៃរដ្ឋាភិបាលថ្នាក់កណ្តាលដែលមិនបានដាក់បញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ | ៦.១. ចំណាយដែលមិនបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ |
| | | ៦.២. ចំណូលដែលមិនបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ |
| | | ៦.៣. របាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាបន្ថែម |
| | PI-៧. ការផ្ទេរធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ៧.១. ប្រព័ន្ធសម្រាប់ធ្វើការបែងចែកធនធាន |
| | | ៧.២. ភាពទាន់ពេលនៃព័ត៌មានការបែងចែកធនធាន |
| | PI-៨. ព័ត៌មានសមិទ្ធកម្មនៃការផ្តល់សេវាសាធារណៈ | ៨.១. ផែនការសមិទ្ធកម្មសម្រាប់ការផ្តល់សេវា |
| | | ៨.២. សមិទ្ធកម្មសម្រេចបានរបស់អង្គភាពផ្តល់សេវា |
| | | ៨.៣. ធនធានដែលបានទទួលដោយអង្គភាពផ្តល់សេវា |
| | | ៨.៤. ការវាយតម្លៃសមិទ្ធកម្មសម្រាប់ការផ្តល់សេវា |
| | PI-៩. ព័ត៌មានហិរញ្ញវត្ថុដែលសាធារណជនអាចស្វែងរកបាន | ៩.១. ព័ត៌មានហិរញ្ញវត្ថុដែលសាធារណៈជនអាចស្វែងរកបាន |
| III. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបំណុល | PI-១០. របាយការណ៍ស្តីពីហានិភ័យហិរញ្ញវត្ថុ | ១០.១. ការតាមដានសហគ្រាសសាធារណៈ |
| | | ១០.២. ការតាមដានរដ្ឋបាលថ្នាក់ក្រោមជាតិ |
| | | ១០.៣. បំណុលមិនបានគ្រោងទុក និងហានិភ័យហិរញ្ញវត្ថុ |
| | PI-១១. ការគ្រប់គ្រងវិនិយោគសាធារណៈ | ១១.១. ការវិភាគសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគ |
| | | ១១.២. ការជ្រើសរើសគម្រោងវិនិយោគ |
| | | ១១.៣. ការគណនាថ្លៃដើមគម្រោងវិនិយោគ |
| | | ១១.៤. ការតាមដានគម្រោងវិនិយោគ |
| | PI-១២. ការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ | ១២.១. ការតាមដានទ្រព្យហិរញ្ញវត្ថុ |
| | | ១២.២. ការតាមដានទ្រព្យមិនមែនហិរញ្ញវត្ថុ |
| | | ១២.៣. តម្លាភាពនៃការជម្រះទ្រព្យសកម្ម |
| | PI-១៣. ការគ្រប់គ្រងបំណុល | ១៣.១. ការកត់ត្រា និងការរាយការណ៍ |
| | | ១៣.២. ការអនុម័តបំណុល និងការធានាបំណុល |
| | | ១៣.៣. យុទ្ធសាស្ត្រគ្រប់គ្រងបំណុល |
| IV. យុទ្ធសាស្ត្រថវិកាផ្អែកលើគោលនយោបាយ | PI-១៤. ការព្យាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៤.១. ការព្យាករម៉ាក្រូសេដ្ឋកិច្ច |
| | | ១៤.២. ការព្យាករចំណូល-ចំណាយ |
| | | ១៤.៣. ការវិភាគអំពីវេទយិតភាព នៃចំណូល-ចំណាយកម្រិតម៉ាក្រូ |
| | PI-១៥. យុទ្ធសាស្ត្រហិរញ្ញវត្ថុ | ១៥.១. ផលប៉ះពាល់ចំណូល-ចំណាយ នៃសំណើគោលនយោបាយ |
| | | ១៥.២. ការអនុវត្តយុទ្ធសាស្ត្រចំណូល-ចំណាយ |
| | | ១៥.៣. ការរាយការណ៍ពីលទ្ធផលចំណូល-ចំណាយ |
| | PI-១៦. ការរៀបចំថវិការយៈពេលមធ្យម | ១៦.១. ការប៉ាន់ស្មានចំណាយរយៈពេលមធ្យម |
| | | ១៦.២. ពិដានចំណាយរយៈពេលមធ្យម |
| | | ១៦.៣. ភាពស្របគ្នារវាងផែនការយុទ្ធសាស្ត្រ និងថវិការយៈពេលមធ្យម |
| | | ១៦.៤. សង្គតិភាពនៃថវិកាជាមួយការប៉ាន់ស្មានពីឆ្នាំមុន |
| | PI-១៧. ដំណើរការរៀបចំថវិកា | ១៧.១. ប្រតិទិនថវិកា |
| | | ១៧.២. ការណែនាំស្តីពីការរៀបចំថវិកា |
| | | ១៧.៣. ការបញ្ជូនថវិកាទៅកាន់អង្គនីតិបញ្ញត្តិ |
| | PI-១៨. ពិនិសច្ច័យថវិកាដោយស្ថាប័ននីតិបញ្ញត្តិ | ១៨.១. ទំហំពិនិសច្ច័យថវិកា |
| | | ១៨.២. នីតិវិធីស្ថាប័ននីតិបញ្ញត្តិសម្រាប់ពិនិសច្ច័យថវិកា |
| | | ១៨.៣. ពេលវេលាអនុម័តថវិកា |
| | | ១៨.៤. វិធានសម្រាប់កែតម្រូវថវិកាដោយស្ថាប័ននីតិប្រតិបត្តិ |
| V. ការប៉ាន់ប្រមាណ និងការត្រួតពិនិត្យការអនុវត្តថវិកា | PI-១៩. រដ្ឋបាលចំណូល | ១៩.១. សិទ្ធិអំណាច និងកាតព្វកិច្ចសម្រាប់ការវាស់វែងចំណូល |
| | | ១៩.២. ការគ្រប់គ្រងហានិភ័យចំណូល |
| | | ១៩.៣. សវនកម្ម និងការស៊ើបអង្កេតចំណូល |

| សសរស្តម្ភ | សូចនាករ | សមាសធាតុ |
|---|---|---|
| | | ១៩.៤. ការត្រួតពិនិត្យបំណុលចំណូលក្នុងឆ្នាំ |
| | PI-២០. គណនេយ្យសម្រាប់ចំណូល | ២០.១. ព័ត៌មានស្ដីពីការប្រមូលចំណូល |
| | | ២០.២. ការបង្វែរការប្រមូលចំណូល |
| | | ២០.៣. ការផ្ទៀងផ្ទាត់គណនីប្រមូលចំណូល |
| | PI-២១. ការព្យាករបាននៃការបែងចែកធនធានក្នុងឆ្នាំ | ២១.១. ការរួមបញ្ចូលគ្នានៃសមតុល្យសាច់ប្រាក់ |
| | | ២១.២. ការព្យាករ និងការតាមដានសាច់ប្រាក់ |
| | | ២១.៣. ព័ត៌មានអំពីពិដានសម្រាប់ការធានាចំណាយ |
| | | ២១.៤. សារៈសំខាន់នៃការតម្រូវឥណទានក្នុងឆ្នាំ |
| | PI-២២. បំណុលកកស្ទះលើចំណាយ | ២២.១. ទំហំបុរេប្រទានមិនទាន់ក្នុងឆ្នាំ |
| | | ២២.២.ការតាមដានបំណុលកកស្ទះលើចំណាយ |
| | PI-២៣. ការត្រួតពិនិត្យបៀវត្ស | ២៣.១. ការប្រៀបធៀបបញ្ចូលគ្នានៃតារាងបៀវត្ស និងបញ្ជីបុគ្គលិក |
| | | ២៣.២. ការគ្រប់គ្រងការប្រែប្រួលបៀវត្ស |
| | | ២៣.៣. ការគ្រប់គ្រងផ្ទៃក្នុងលើបៀវត្ស |
| | | ២៣.៤. សវនកម្មលើបៀវត្ស |
| | PI-២៤. ការគ្រប់គ្រងលទ្ធកម្ម | ២៤.១. ការត្រួតពិនិត្យលទ្ធកម្ម |
| | | ២៤.២. វិធីសាស្ត្រលទ្ធកម្ម |
| | | ២៤.៣. ការបើកចំហជាសាធារណៈនូវព័ត៌មានលទ្ធកម្ម |
| | | ២៤.៤. ការគ្រប់គ្រងបណ្ដឹងលទ្ធកម្ម |
| | PI-២៥. ការត្រួតពិនិត្យផ្ទៃក្នុងលើការចំណាយមិនមែនបៀវត្ស | ២៥.១. ការបែងចែកតួនាទី និងភារកិច្ច |
| | | ២៥.២. ប្រសិទ្ធភាពនៃការគ្រប់គ្រងការធានាចំណាយ |
| | | ២៥.៣. អនុលោមភាពតាមវិធាន និងនីតិវិធីនៃការទូទាត់ |
| | PI-២៦. សវនកម្មផ្ទៃក្នុង | ២៦.១. វិសាលភាពសវនកម្មផ្ទៃក្នុង |
| | | ២៦.២. លក្ខណៈនៃសវនកម្ម និងស្តង់ដារដែលត្រូវប្រើប្រាស់ |
| | | ២៦.៣. ការអនុវត្តសវនកម្មផ្ទៃក្នុង និងការធ្វើរបាយការណ៍ |
| | | ២៦.៤. ការឆ្លើយតបនឹងសវនកម្មផ្ទៃក្នុង |
| VI. គណនេយ្យ និងរបាយការណ៍ | PI-២៧. ការប្រមូលសរុបទិន្នន័យហិរញ្ញវត្ថុ | ២៧.១. ការផ្ទៀងផ្ទាត់គណនីធនាគារ |
| | | ២៧.២. គណនីបណ្ដោះអាសន្ន |
| | | ២៧.៣. គណនីបុរេប្រទាន |





| សសរស្តម្ភ | សូចនាករ | សមាសធាតុ |
|---|---|---|
| | | ២៧.៤. កិច្ចដំណើរការនៃការប្រមូលបញ្ចូលទិន្នន័យហិរញ្ញវត្ថុ |
| | PI-២៨. របាយការណ៍ថវិកាឆ្នាំអនុវត្ត | ២៨.១. វិសាលភាព និងការប្រៀបធៀបរបាយការណ៍ |
| | | ២៨.២. រយៈពេលរៀបចំរបាយការណ៍ថវិកាក្នុងឆ្នាំអនុវត្ត |
| | | ២៨.៣. សុក្រឹតភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំអនុវត្ត |
| | PI-២៩. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | ២៩.១. ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ |
| | | ២៩.២. ការរៀបចំរបាយការណ៍សម្រាប់សវនកម្មផ្ទៃក្រៅ |
| | | ២៩.៣. ស្តង់ដារគណនេយ្យ |
| VII. ត្រួតពិនិត្យខាងក្រៅ និងសវនកម្ម | PI-៣០. សវនកម្មផ្ទៃក្រៅ | ៣០.១. វិសាលភាព និងស្តង់ដារសវនកម្ម |
| | | ៣០.២. ការផ្ដល់នូវរបាយការណ៍សវនកម្ម |
| | | ៣០.៣. ការតាមដានរបស់សវនកម្មផ្ទៃក្រៅ |
| | | ៣០.៤. ការធ្វើសវនកម្មរបស់ស្ថាប័នឯករាជ្យ |
| | PI-៣១. របាយការណ៍សវនកម្មរបស់អង្គនីតិប្បញ្ញត្តិ | ៣១.១. កាលបរិច្ឆេទនៃការត្រួតពិនិត្យរបាយការណ៍សវនកម្ម |
| | | ៣១.២. ការស្ដាប់ចម្លើយលើរបកគំហើញសវនកម្ម |
| | | ៣១.៣. អនុសាសន៍សវនកម្មដោយអង្គនីតិប្បញ្ញត្តិ |
| | | ៣១.៤. តម្លាភាពនៃការត្រួតពិនិត្យក្របខណ្ឌគតិយុត្តនៃរបាយការណ៍សវនកម្ម |

# ផ្នែកទី ៣ ៖ ទស្សនៈ និងមតិ



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

*"ក្នុងពេលខាងមុខ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងឈានដល់ជំហាន និងដំណាក់កាលចុងក្រោយ គឺ <<**គណនេយ្យភាពសមិទ្ធកម្ម**>> ដែលតម្រូវឱ្យមានការចូលរួមរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តផែនការសកម្មភាពរៀងៗខ្លួន ដោយបុរេសកម្ម និងគណនេយ្យភាព។ ក្នុងការបន្តអនុវត្តកម្មវិធីនេះ ខ្ញុំសូមឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្តប្រកាន់ខ្ជាប់នូវស្មារតីនៃភាពប្រាកដនិយម និងភាពជាម្ចាស់ខ្ពស់ ព្រមទាំងអភិក្រមទន់ភ្លន់ តែម៉ឺងម៉ាត់នៅក្នុងការអនុវត្តស្របតាមគោលការណ៍ <<**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់**>> ។"*



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*"ការងារកែទម្រង់ជាការងារ **ស្លាប់-រស់** របស់ប្រទេសជាតិទាំងសម្រាប់ពេលបច្ចុប្បន្ន និងជាពិសេសសម្រាប់អនាគត ដែលប្រការនេះតែងត្រូវបានលើកឡើងដោយសម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ការកែទម្រង់មានគោលបំណងដើម្បីលើកកម្ពស់ភាពប្រសើរឡើងនៃអភិបាលកិច្ចល្អ និងសេវាសាធារណៈ ជូនដល់ប្រជាពលរដ្ឋ ជាពិសេសគឺយុវជន ហើយដែលយុវជន គឺជាកម្លាំងដ៏មានសក្តានុពលបំផុត ផ្សារភ្ជាប់នឹងការងារកែទម្រង់។ ដូចនេះ ខ្ញុំអាចនិយាយបានថា បុព្វហេតុនៃការកែទម្រង់គឺដើម្បីយុវជន រីឯបុព្វហេតុយុវជនគឺដើម្បីការកែទម្រង់ សំដៅឆ្ពោះទៅកាន់គ្រើយតែមួយ គឺការអភិវឌ្ឍ និងវិបុលភាពនៃប្រទេសជាតិរបស់យើង។"*

*"ការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងសាធារណៈ គឺជាកិច្ចការដែលមានលក្ខណៈសាំញ៉ាំ ស្មុគស្មាញ និងមានផលប៉ះពាល់ទាំងទៅលើផ្នែកបុគ្គល និងផ្នែកស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រូវការប្រើប្រាស់ពេលវេលាពីមធ្យមទៅវែង។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ទាំងនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព តម្រូវឱ្យមានការតាំងចិត្តផ្នែកនយោបាយយ៉ាងច្បាស់លាស់ពីជួររាជរដ្ឋាភិបាលទាំងមូល និងតម្កល់ការតាំងចិត្តនេះឱ្យនៅស្ថិតស្ថេរជារៀងរហូត។ ពាក់ព័ន្ធនឹងលក្ខខណ្ឌនេះ នាពេលកន្លងមក ប្រមុខដឹកនាំរាជរដ្ឋាភិបាលមានការតាំងចិត្តខ្ពស់ និងយ៉ាងមុតស្រួចចំពោះកម្មវិធីកែទម្រង់ទាំងនេះ ដោយបានដាក់បញ្ចូលការកែទម្រង់ទាំងនេះធ្វើជាស្នូលនៃគោលនយោបាយជាតិ រួមមាន÷ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១, ដំណាក់កាលទី២ និងដំណាក់កាលទី៣ ជាដើម។"*



**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ជ.អ.ប.**

*"ការសម្រេចដាក់ឱ្យអនុវត្តថវិកាកម្មវិធី ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់នូវលទ្ធផលខ្លះៗ ដែលអាចចូលរួមក្នុងការកែលម្អជាបណ្តើរៗលើប្រព័ន្ធថវិកាកម្ពុជា។ សមិទ្ធផលទាំងនេះ រួមបញ្ចូលទាំងការពង្រឹងសមត្ថភាពដើម្បីទ្រទ្រង់ដល់ការអនុវត្តថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានថវិកា, កែលម្អវិន័យថវិកាលើការអនុវត្តការចំណាយរបស់ក្រសួង-ស្ថាប័ន, លើកកម្ពស់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងថវិកាតាមរយៈការបង្កើតអង្គភាពថវិកា, និងជាពិសេសគឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។"*




ដកស្រង់ចេញពីសៀវភៅ Alterative Paths to Public Financial Management and Public Sector Reform ដែលបោះពុម្ពផ្សាយដោយធនាគារពិភពលោក។




# ផ្នែកទី ៤ ÷ សុន្ទរកថា

# សុន្ទរកថាគន្លឹះរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុង "កម្មវិធីបើកកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*នាថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។*




*សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក សមាជិកា នៃរាជរដ្ឋាភិបាល, ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ, ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយ ដែលបានមកចូលរួមជាមួយសម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាការដ្ឋានកែទម្រង់ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល និងដែលត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ ចាប់តាំងពីឆ្នាំ២០០៤ មក។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ធ្វើការកត់សម្គាល់ប្រកបដោយការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពដែលកម្មវិធីកែទម្រង់នេះសម្រេចបាន ក្នុងរយៈពេលប្រមាណជាង ១៣ ឆ្នាំកន្លងមក ជាពិសេសវឌ្ឍនភាពថ្មីៗ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដែលការកែទម្រង់របស់យើងស្ថិតក្នុងសភាពការណ៍ប្រែប្រួលឆាប់រហ័ស, ទាំងនៅក្នុង និងក្រៅប្រទេស,ដែលខ្ញុំតែងហៅថាសភាពការណ៍ចល័ត។ ប្រការនេះ បានផ្តល់ឱកាសឱ្យយើងបន្តការងារកែទម្រង់ផង និងធ្វើការសាកល្បងលើ <<**ភាពឆ្លើយតបនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**>> របស់យើងផង, ជាពិសេសភាពឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ថ្មីៗ និងបំណងប្រាថ្នាកើនឡើងឥតឈប់ឈររបស់ប្រជាជនយើងក្រោយពីការកែទម្រង់នេះ បានឆ្លងកាត់ដំណាក់កាល២ សំខាន់ៗ ក្នុងការគាំទ្រនូវការសម្រេចអាទិភាពគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាលដែលមានលក្ខណៈកាន់តែលំបាក និងកាន់តែស្មុគស្មាញឡើង។

*ពេលនេះ យើងកំពុងតែស្ថិតក្នុងដំណើររួមគ្នាជាមួយនឹងប្រជាជនកម្ពុជាទាំងមូល ឆ្ពោះទៅសម្រេចឱ្យខានតែបាននូវគោលដៅយុទ្ធសាស្ត្រទី៣ ចុងក្រោយ ដែលបុព្វហេតុរួមសម្រាប់កសាងអនាគតរុងរឿងនៃប្រទេសជាតិយើង។*

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

នៅក្នុងដំណើរនៃការដឹកនាំប្រទេសជាតិក្នុងរយៈពេលកន្លងមក, ខ្ញុំបានលះបង់ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបម្រើនូវគោលដៅយុទ្ធសាស្ត្រគន្លឹះចំនួន ៣ រួមមាន÷

ទី១) ការដឹកនាំតស៊ូរំដោះប្រជាជន និងប្រទេស ឱ្យរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត; ទី២) ការទប់ស្កាត់មិនឱ្យរបបប្រល័យពូជសាសន៍វិលត្រលប់មកវិញ; ទី៣) ការបណ្តុះបណ្តាល, ពង្រឹង និងពង្រីកវប្បធម៌សន្តិភាព និងការការពារឱ្យបានដាច់ខាតនូវសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម ដែលសម្រេចបានមកដោយលំបាកលំបិនជាទីបំផុតនេះ ដើម្បីសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍប្រទេស និងវឌ្ឍនភាពសង្គម។ នៅលើបន្ទាត់ប្រវត្តិសាស្ត្រនេះ, ខ្ញុំអាចនិយាយបានថា ខ្ញុំសម្រេចបានរួចហើយ នូវគោលដៅជាយុទ្ធសាស្ត្រពីរខាងដើម តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០; ហើយពេលនេះ កំពុងតែស្ថិតក្នុងដំណើររួមគ្នាជាមួយនឹងប្រជាជនកម្ពុជាទាំងមូល ឆ្ពោះទៅសម្រេចឱ្យខានតែបាន នូវគោលដៅយុទ្ធសាស្ត្រទី៣ ចុងក្រោយ ដែលបុព្វហេតុរួមសម្រាប់កសាងអនាគតរុងរឿងនៃប្រទេសជាតិយើង។ ក្នុងបេសកកម្មការពារសន្តិភាព និងអភិវឌ្ឍជាតិ ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ, ខ្ញុំបានសង្កេតឃើញច្បាស់ថា ប្រជាជនកម្ពុជា, ជានិច្ចកាល,តែងតែជ្រោងខ្ពស់នៅទង់សន្តិភាព



និងការអភិវឌ្ឍ ដែលជាកម្លាំងដ៏ខ្លាំងក្លា ធ្វើឱ្យបរាជ័យដល់ការប៉ុនប៉ងទាំងឡាយ ដើម្បីរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ចូលក្នុងភាពចលាចល និងភាពវឹកវរផ្នែកនយោបាយ។

ជាការពិត នៅក្នុងការងារដឹកនាំជំរុញការអភិវឌ្ឍប្រទេស សន្តិភាព និងស្ថិរភាពនយោបាយ ត្រូវបានចាត់ទុកជា បុព្វលក្ខខណ្ឌដ៏ចម្បង និងសំខាន់បំផុត នៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលជាលក្ខខណ្ឌចាំបាច់



សម្រាប់ជំរុញឱ្យមានវឌ្ឍនភាព, ការអភិវឌ្ឍ និងវិបុលភាពនៅក្នុងសង្គមជាតិ។ នៅក្នុងអាណត្តិនេះ, កម្ពុជាសម្រេចបាននូវបង្គោលចរដ៏សំខាន់មួយក្នុងការអភិវឌ្ឍ ពោលគឺការប្រែក្លាយខ្លួនពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងធ្វើដំណើរឆ្ពោះទៅសម្រេចបានការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) នៅក្នុងពេលខាងមុខ។ សក្តានុពលសេដ្ឋកិច្ចកម្ពុជាត្រូវបានទទួលស្គាល់ និងចាត់ទុកថាជា ខ្លាសេដ្ឋកិច្ចថ្មីមួយ ក្នុងតំបន់អាស៊ី។ ច្បាស់ណាស់ថា, នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការ និងឧបករណ៍មិនអាចខ្វះបាន, មិនត្រឹមតែក្នុងការសម្រេចបានគោលដៅខាងលើប៉ុណ្ណោះទេ; ប៉ុន្តែសម្រាប់ការខិតខំដើម្បីសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយកម្ពុជា ទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

ថ្វីត្បិតការត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងតែត្រូវបានរៀបចំជាប្រចាំឆ្នាំ និងតាមដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ ប៉ុន្តែ កិច្ចប្រជុំលើកនេះក៏មានការបូកសរុបវឌ្ឍនភាពរយៈពេល ៥ ឆ្នាំផងដែរ ដែលស្របគ្នានឹងការបញ្ចប់អាណត្តិទី៥ របស់រាជរដ្ឋាភិបាល។

*សក្តានុពលសេដ្ឋកិច្ចកម្ពុជាត្រូវបានទទួលស្គាល់ និងចាត់ទុកថាជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី។*

ក្នុងន័យនេះ, ខ្ញុំសូមធ្វើការកត់សម្គាល់ក៏ដូចជាវាយតម្លៃមួយចំនួនចំពោះវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷

ទី១) ការសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពនៃហិរញ្ញវត្ថុសាធារណៈ ដែលរួមមានជាអាទិ៍÷ ការធានាបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ក្នុងរង្វង់៧%; ការរក្សាបាននូវអត្រាអតិផរណាប្រចាំឆ្នាំទាប ក្នុងរង្វង់ ៣% ជាមួយនឹងអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងរង្វង់ ៤០០០រៀលក្នុង ១ដុល្លារអាមេរិក; ការគ្រប់គ្រងបាននូវឱនភាពថវិកាប្រចាំឆ្នាំ នៅក្នុងកម្រិតក្រោម ៥% នៃផសស; និងការគ្រប់គ្រងបំណុលសាធារណៈបានល្អប្រសើរ។

លើសពីនេះ, ការគ្រប់គ្រងថវិកាជាតិក៏កាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, សុក្រិតភាព, តម្លាភាព, និងគណនេយ្យភាពល្អប្រសើរជាងមុន ដែលប្រការនេះបានរួមចំណែកយ៉ាងសំខាន់ ដល់ការលើកកម្ពស់ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ប្រកបដោយគុណភាព, ហើយបានផ្តល់នូវបច្ច័យវិជ្ជមានដល់ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបានរួមចំណែកកាត់បន្ថយភាពក្រីក្របានច្រើនជាង ១% ក្នុង ១ ឆ្នាំៗ។



ទី២) ការសម្រេចបាននូវភាពជឿទុកចិត្តពេញលេញនៃថវិកាជាតិ ដែលឆ្លុះបញ្ចាំងឡើងតាមរយៈការធានាបាននូវអតិរេកសាច់ប្រាក់ជាប្រចាំ, ការកើនឡើងនៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល និងការបើកផ្តល់ប្រាក់បៀវត្សដែលមានកំណើនជាលំដាប់នៅរាល់សប្តាហ៍ទី៤ នៃខែនីមួយៗ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ក្នុងការពង្រឹងយន្តការប្រមូលចំណូល ដែលត្រូវបានកែលម្អឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ដោយមិនបានពង្រីកមុខសញ្ញា ឬបង្កើតប្រភេទពន្ធថ្មីៗឡើយ; ប៉ុន្តែ លើសពីនេះ, ថែមទាំងបានលុបចោលនូវប្រភេទពន្ធ ឬកែសម្រួលកាត់បន្ថយនូវអត្រាពន្ធ និងចំណូលមិនមែនសារពើពន្ធមួយចំនួនថែមទៀតស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធដល់សកម្មភាពធុរកិច្ច និងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាការពិតកំណើនចំណូលចរន្តនៃថវិកាជាតិ, ក្នុងសន្ទុះប្រមាណជិត ១ ពិន្ទុភាគរយនៃផសស ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ, បានបង្ហាញយ៉ាងច្បាស់អំពីលទ្ធផលល្អប្រសើរនៃកិច្ចខិតខំប្រឹងប្រែងនេះ។ ជាមួយគ្នានេះ ការរៀបចំថវិកាប្រចាំឆ្នាំ ក៏ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ ដោយធានាបាននូវការវិភាជឥណទានថវិកាសមស្របសម្រាប់អនុវត្តសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយថវិកាក៏ត្រូវបានផ្តល់ទៅដល់ដៃអ្នកអនុវត្តសកម្មភាពផ្ទាល់ នៅតាមក្រសួង-ស្ថាប័ន, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។




ទី៣) ការឆ្លើយតបបានទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាល និងសំណូមពរថ្មីៗរបស់ប្រជាជន ពោលគឺរាជរដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបទៅនឹងសំណូមពរកាន់តែខ្ពស់របស់ប្រជាជន ស្របទៅតាមការកើនឡើងនូវសមត្ថភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិ រួមមាន÷ ការឆ្លើយតបទាន់ពេលវេលាទៅនឹងសភាពការណ៍បន្ទាន់នានាជាអាទិ៍÷ គ្រោះធម្មជាតិ វិបត្តិនៅតាមបន្ទាត់ព្រំដែន, និងតម្រូវការអន្តរាគមន៍ភ្លាមៗ ក្នុងវិស័យស្រូវ/អង្ករ; ការពង្រីកវិសាលភាពនៃការគាំពារផ្នែកសង្គម, ទាំងក្នុងក្របខណ្ឌមន្ត្រីរាជការសាធារណៈ និងក្នុងចំណោមកម្មករ, ទាំងក្នុង និងក្រៅប្រព័ន្ធ; ការវិនិយោគលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមការចាំបាច់; ការដកហូតយកមកគ្រប់គ្រងវិញនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងរូបភាពជាដៃគូរដ្ឋ និងឯកជន ដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃការសម្រួលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ក៏ដូចជាក្នុងទិសដៅឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ជាដើម។ល។

ទី៤) ការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាក្របខណ្ឌសម្រាប់រាជរដ្ឋាភិបាលកម្ពុជាអាចពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែល្អប្រសើរថែមទៀត រួមមានការកាត់បន្ថយចំណាយក្រៅផ្លូវការពាក់ព័ន្ធនឹងប្រតិបត្តិការហិរញ្ញវត្ថុផងដែរ។

ការសម្រេចចិត្តដ៏តន្លឹះមួយនៃការបើកបៀវត្ស និងប្រាក់សោធនតាមប្រព័ន្ធធនាគារ អាចឱ្យយើងបញ្ចប់បានទាំងស្រុងនូវបញ្ហារ៉ាំរ៉ៃនៃចំណាយក្រៅផ្លូវការ និងភាពយឺតយ៉ាវពាក់ព័ន្ធនឹងការបើកផ្តល់ប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការសាធារណៈ និងប្រាក់សោធនសម្រាប់និវត្តជន។ ជារួម ខ្ញុំរំពឹងថា នៅពេលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណើរការបានពេញលេញ ការគ្រប់គ្រងចំណាយថវិការរដ្ឋនឹងកាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និងគណនេយ្យភាពល្អប្រសើរឡើងថែមទៀត; ហើយប្រព័ន្ធនេះ នឹងជួយផ្តល់ព័ត៌មានយ៉ាងពេញលេញ និងទាន់ពេល អំពីស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ការវិភាគ និងការធ្វើសេចក្តីសម្រេចចិត្តលើការបែងចែក និងប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈសរុបជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់។



ទី៥) ការដាក់ចេញនូវទិសដៅ និងសកម្មភាពច្បាស់លាស់ ក្នុងការងារកែទម្រង់ ដោយជំរុញការអនុវត្តជាប្រចាំប្រកបដោយអភិក្រមទន់ភ្លន់, ភាពប្រាកដនិយម និងភាពជាម្ចាស់ខ្ពស់។ ជាក់ស្តែង នៅពេលចាប់ផ្តើមក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលរំពឹងថាកម្មវិធីនេះ នឹងអាចចប់នៅឆ្នាំ២០១៥។ ប៉ុន្តែ យោងតាមតម្រូវការជាក់ស្តែង យើងបានធ្វើការកែតម្រូវយុទ្ធសាស្ត្រ, កម្មវិធី និងពេលវេលានៃការអនុវត្តជាបន្តបន្ទាប់ ដើម្បីសម្របទៅតាមស្ថានភាព និងលទ្ធភាពរបស់កម្ពុជា។ ក្នុងគោលដៅតម្រង់ទិសនៃសកម្មភាពកែទម្រង់សម្រាប់រយៈពេលវែងទៅមុខ, រាជរដ្ឋាភិបាលទើបនឹងបានអនុម័តឯកសារ <<**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨ - ២០២៥**>> ដែលខ្ញុំនឹងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្នុងពេលបន្តិចទៀតនេះ។ ឯកសារនេះ គឺជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងសម្រាប់ដំណាក់កាលទី៣ ឈានចូលទៅដំណាក់កាលទី៤ បន្តទៀត ហើយត្រូវបានរៀបចំឡើង ដោយធានាបានដ៏ពេញលេញនូវភាពជាម្ចាស់របស់កម្ពុជា និងមានលក្ខណៈជាក់ស្តែងនិយមស្របទៅតាមបរិការណ៍កម្ពុជាក្នុងគោលដៅប្រែក្លាយថវិកាឱ្យទៅជាឧបករណ៍គោលនយោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍប្រទេស។

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*



ក្នុងពេលខាងមុខ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងឈានដល់ជំហាន និងដំណាក់កាលចុងក្រោយ គឺ <<**គណនេយ្យភាពសមិទ្ធកម្ម**>> ដែលតម្រូវឱ្យមានការចូលរួមរបស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តផែនការសកម្មភាពរៀងៗខ្លួន ដោយបុរេសកម្ម និងគណនេយ្យភាព។ ក្នុងការបន្តអនុវត្តកម្មវិធីនេះ ខ្ញុំសូមឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្តប្រកាន់ខ្ជាប់នូវស្មារតីនៃភាពប្រាកដនិយម និងភាពជាម្ចាស់ខ្ពស់ ព្រមទាំងអភិក្រមទន់ភ្លន់, តែម៉ឺងម៉ាត់នៅក្នុងការអនុវត្តស្របតាមគោលការណ៍ <<**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់**>> ដោយផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម÷

ទី១) ការបង្កើនភាពជាម្ចាស់ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង-ស្ថាប័ន។ រដ្ឋមន្ត្រី និងប្រធានស្ថាប័ន ត្រូវមានភាពជាម្ចាស់ ក្នុងការជំរុញការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមគោលការណ៍រួមរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងការពុះពារសម្រេចឱ្យបាននូវគោលបំណង និងបេសកកម្មរបស់ក្រសួង-ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ អាស្រ័យនេះ, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវចាត់ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាការងារដែលត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តជាប្រចាំ។ ជាមួយគ្នានេះ, គ្រប់ក្រសួង-ស្ថាប័ន ត្រូវផ្តោតអាទិភាពទៅលើការពង្រឹងភាពជាអ្នកដឹកនាំ និងរចនាសម្ព័ន្ធគ្រប់គ្រងស្របគ្នានឹងការពង្រឹងសមត្ថភាព និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវធនធានមន្ត្រីរាជការ នៅក្រោមឱវាទ សំដៅកែលម្អសមិទ្ធកម្មនៅក្នុងការអនុវត្ត។



ទី២) ការផ្តល់ការលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន។ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញរួចហើយនូវវិធានការ និងយន្តការផ្តល់ការលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ដោយផ្អែកលើលទ្ធផលការងារនៃការកែទម្រង់។ ដូច្នេះ ខ្ញុំសូមណែនាំឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាប្រធានស្ថាប័ន និងក្រុមការងារកែទម្រង់នៅតាមក្រសួង-ស្ថាប័ន ជំរុញអនុវត្តការងារនេះ យ៉ាងសកម្ម ក្លៀវក្លា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ទី៣) ការបន្តពង្រឹងយន្តការសម្របសម្រួល និងភាពប្រទាក់ក្រឡាគ្នារវាងការកែទម្រង់ទាំង៣ ដែលរួមមាន ÷ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។ អភិបាលកិច្ចល្អ ត្រូវការសមាសធាតុទាំងបី គឺ÷ ការគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព, ធនធានមនុស្សប្រកបដោយគុណភាព, និងការធ្វើប្រតិភូកម្មអំណាចត្រឹមត្រូវ។ ក្នុងន័យនេះ យើងចាំបាច់ត្រូវរក្សាឱ្យបាននូវសង្គតិភាពនៃកម្មវិធីកែទម្រង់ទាំង៣នេះ ទាំងក្នុងទិដ្ឋភាពក្របខណ្ឌរួម, ទាំងក្នុងទិដ្ឋភាពនៃការអនុវត្ត, សំដៅធានាបាននូវសុខដុមភាព, ភាពប្រទាក់ក្រឡា និងការបំពេញគ្នាទៅវិញទៅមក។ ពិតណាស់ថា ប្រសិនបើការកែទម្រង់ទាំង៣ ស្ថិតនៅក្នុងទិសដៅផ្ទុយគ្នា និងមានល្បឿនខុសគ្នា នោះប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់នីមួយៗ ក៏នឹងមានកំណត់ផងដែរ។

ទី៤) ការយកចិត្តទុកដាក់ខ្ពស់ដល់ការអនុវត្ត <<**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**>>។ ដូចខ្ញុំបានលើកឡើងពីខាងលើ ចំណុចស្នូល ឬឆ្អឹងខ្នងនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ គឺការកែទម្រង់ប្រព័ន្ធថវិកាជាតិ សំដៅប្រែក្លាយថវិកាឱ្យទៅជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពសម្រាប់ធានាសម្រេចបាននូវគោលបំណងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការកៀរគរធនធានរបស់ជាតិប្រកបដោយចីរភាព និងការវិភាជធនធានទាំងនោះសម្រាប់បម្រើឱ្យគោលដៅនៃការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់។ អាស្រ័យហេតុនេះ, យើងត្រូវក្តាប់ឱ្យជាប់នូវឱកាស និងបង្កើតលក្ខខណ្ឌល្អប្រសើរ ដើម្បីជំរុញអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ទៅតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជាឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវចាត់ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាការងារដែលត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តជាប្រចាំ។*

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

លទ្ធផល, សមិទ្ធផល, និងវឌ្ឍនភាព, ដែលសម្រេចបានមកដល់ពេលនេះ, ពិតជាមិនអាចកាត់ផ្តាច់បានពីការចូលរួមចំណែក

របស់គ្រប់ស្ថាប័នទាំងអស់ ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចាប់តាំងពីឆ្នាំ២០០៤ មក ជាពិសេសក្នុងចំណោមថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ ដែលជាប់ពាក់ព័ន្ធតាំងពីដំបូងរហូតមកដល់ពេលនេះ។

ទន្ទឹមនឹងនេះ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់, ការកោតសរសើរ, និងអំណរគុណ, ជូនចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងឯកឧត្តម និងលោកជំទាវ, ជារដ្ឋមន្ត្រីក្រសួង និងប្រធានស្ថាប័ន, ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងប្ដូរផ្ដាច់ក្នុងការដឹកនាំ និងសហការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយឆន្ទៈភ្លៀវក្លា ព្រមទាំងស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានជោគជ័យគួរជាទីមោទនៈ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ដែលតែងតែផ្តល់ការគាំទ្រ ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈកិច្ចសម្របសម្រួល និងកិច្ចសហការជាប្រចាំជាមួយក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល នៅក្នុងអភិក្រមគ្របដណ្តប់ទូទាំងវិស័យ និងដោយគោរពភាពជាម្ចាស់របស់កម្ពុជា ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នេះ។

មុននឹងបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរ សូមឱ្យសុឆន្ទៈ, ភាពជាម្ចាស់, ការទទួលខុសត្រូវ, កិច្ចខិតខំប្រឹងប្រែង, ការរួមចំណែក, និងកិច្ចសហប្រតិបត្តិការដ៏ល្អទាំងអស់នេះ, កាន់តែរីកដុះដាលរឹងមាំឡើងជាលំដាប់ថែមទៀត ជាមូលដ្ឋានសម្រាប់ធានាបាននូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីបុព្វហេតុនៃឧត្តមប្រយោជន៍របស់ប្រទេស និងប្រជាជនកម្ពុជា។




ជាទីបញ្ចប់ ក្នុងឱកាសឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២, ដែលទើបនឹងចូលមកដល់ថ្មីៗនេះ សូមសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ទទួលបានសព្វសារធុការពរសិរីសួស្តី, ទទួលបានជោគជ័យក្នុងភារកិច្ចរៀងៗខ្លួន និងសូមឱ្យសមប្រកបដោយព្រះពុទ្ធពរទាំង៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ក្នុងឱកាសដ៏មហោឡារិកនេះ, ខ្ញុំសូមប្រកាសបើក <<**កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**>> និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ <<**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥** ចាប់ពីពេលនេះទៅ៕■

# របាយការណ៍បូកសរុបរបស់បណ្ឌិត ហ៊ែល ចំរើន អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង អ.គ.ហ. ថ្លែងក្នុងកម្មវិធីបិទ "សិក្ខាសាលាស្តីពី បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា"

*នាថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ ២០១៨ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហការជាមួយគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងសហភាពសហព័ន្ធយុវជនកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពី* ***"បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យ នៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា"***

*សម្តេចក្រឡាហោម* ***ស ខេង*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាទីគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុត,*

*ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរាជរដ្ឋាភិបាល ជាគណៈអធិបតី*

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ថ្នាក់ដឹកនាំ និងសមាជិក សមាជិកា សហភាពសហព័ន្ធយុវជនកម្ពុជា ទូទាំងប្រទេស និងបងប្អូនយុវជនជាទីគោរពរាប់អានដ៏ជ្រាលជ្រៅ!*



ក្នុងនាមអង្គសិក្ខាសាលាទាំងមូល ខ្ញុំបាទសូមឧត្តមានុញ្ញាតគោរពថ្លែងកតញ្ញូតាធម៌ និងកតវេទិតាធម៌ ដ៏ស្មោះស្ម័គ្របំផុត គោរពជូន សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃថ្លៃថ្លាយ៉ាងវិសេស អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលាស្តីពី "បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា" ប្រកបដោយភាពជាអ្នកដឹកនាំដ៏វិសេសឆ្នើម និងពោរពេញដោយចក្ខុវិស័យនាំមុខ និងវែងឆ្ងាយលើការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា។

នៅក្រោម "**អគ្គមគ្គទេសក៍ជាញ្ញជ័យ**" នៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិយើងត្រូវបានស្រោចស្រង់ចាកចេញផុតដោយជោគជ័យពីភ្នក់ភ្លើងសង្គ្រាមឆេះសន្ធោសន្ធៅ និងឧក្រិដ្ឋកម្មកាប់សម្លាប់បង្ហូរឈាមពាសពេញទឹកដីមកដល់ដំណាក់កាលថ្មីនៃសុខសន្តិភាព ស្ថិរភាព វិបុលភាព វឌ្ឍនភាព សេរីភាព ឯកភាពជាតិ ឯកភាពទឹកដី ដែលកំពុងស្រោចស្រពដល់ការចម្រើនលូតលាស់នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងជ្រកក្រោមព្រះរាជតេជះព្រះម្លប់បារមីនៃព្រះមហាក្សត្រ ព្រះចៅក្រុងកម្ពុជាធិបតី ដែលជាការបន្តនូវព្រះបរមរាជបវេណីខ្មែរពីបុរាណរាប់ពាន់ឆ្នាំនៃជាតិមាតុភូមិដ៏បវរនៃយើង។



នៅក្រោមបរិយាកាសដ៏នក្ខត្តឫក្សនៃសុខសន្តិភាព ស្ថិរភាព និងវឌ្ឍនភាព ដ៏កម្រមានក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរជាង ៥០០ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តបោះជំហានថ្មីដ៏ថ្កុំថ្កើង នៅលើវិថីនៃការកែទម្រង់ស៊ីជម្រៅ និងទូលំទូលាយ គួរជាទីសង្ឃឹម និងជឿជាក់រឹងមាំនៃប្រជាពលរដ្ឋកម្ពុជានៅក្រោម "**អគ្គមគ្គទេសក៍កែទម្រង់**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយបានផ្តល់កាលានុវត្តភាព និងទេសានុវត្តភាពដ៏ប្រពៃ ដ៏ថ្លៃថ្លាជូនដល់យុវជន យុវមន្ត្រីរាជការសាធារណៈ បានចូលរួមចំណែកក្នុងការងារកែទម្រង់របស់រាជរដ្ឋាភិបាលតាមរយៈការប្រឡូកអនុវត្តដោយផ្ទាល់ តាមរយៈការផ្តល់មតិយោបល់កែលម្អ ឬតាមរយៈការស្វែងយល់ និងតាមដានវឌ្ឍនភាពការងារ ជារឿយៗ ជាប់មិនដាច់ ជារៀងដរាបមក ជាក់ស្តែង ដូចសិក្ខាសាលានាថ្ងៃនេះជាកសិណស្រាប់។ នៅក្នុងបរិការណ៍ដ៏ប្រពៃថ្លៃថ្លានេះ ដោយមានការចង្អុលបង្ហាញណែនាំដ៏ខ្ពង់ខ្ពស់ គត់មត់ និងជាប់ជាប្រចាំរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខ្ញុំបាទសូមឧត្តមានុញ្ញាតចូលខ្លួនគោរពរាយការណ៍បូកសរុបជូនសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម លោកជំទាវ ជាគណៈអធិបតី អំពីលទ្ធផលនៃសិក្ខាសាលាស្តីពីបុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃនេះ តាមខ្លឹមសារគន្លឹះ ជាអាទិ៍ ដូចតទៅ÷

*នៅក្រោមបរិយាកាសដ៏នក្ខត្តឫក្សនៃសុខសន្តិភាព ស្ថិរភាព និងវឌ្ឍនភាព ដ៏កម្រមានក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរជាង ៥០០ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តបោះជំហានដ៏ថ្កុំថ្កើង នៅលើវិថីនៃការកែទម្រង់ស៊ីជម្រៅ និងទូលំទូលាយគួរជាទីសង្ឃឹម និងជឿជាក់រឹងមាំនៃប្រជាពលរដ្ឋកម្ពុជា*

## ទី១) ទស្សនៈ

បានប្រមូលផ្តុំដោយបទបង្ហាញអំពីការងារកែទម្រង់ស្នូលទាំង៤ របស់រាជរដ្ឋាភិបាលកម្ពុជាដោយវាគ្មិនដ៏មានគុណវុឌ្ឍិបរិបូរក្នុងឋានៈជាអ្នកកាន់ការដោយផ្ទាល់លើការងារកែទម្រង់ជាគន្លឹះទាំង៤។

ចំពោះកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ឯកឧត្តម **គង់ សុភី** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានបង្ហាញយ៉ាងជាក់ច្បាស់ថា ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឱ្យមានគុណវុឌ្ឍិ និងស្តង់ដារវិជ្ជាជីវៈស្របតាមឧត្តមានុវត្តន៍អន្តរជាតិ, ការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងការអភិវឌ្ឍយន្តការស្ថាប័នប្រកបដោយវិចារណញ្ញាណ ប្រសិទ្ធភាព និងកិច្ចដំណើរការជាប្រព័ន្ធ នៃស្ថាប័នសាធារណៈ, ការកែទម្រង់បានសម្រេចជាសា-

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



វឌ្ឍ នូវការកែលម្អប្រព័ន្ធបៀវត្ស និងប្រាក់បំណាច់នានា (មានការដំឡើងបៀវត្សមន្ត្រីរាជការដល់លើសពីមួយលានរៀល, ការបើកបៀវត្សទៀងទាត់ និងដល់សាមីខ្លួន) ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការរៀបចំជាថ្មីនូវប្រព័ន្ធមុខងារសាធារណៈ អង្គវិជ្ជាជីវៈ ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីរាជការ ការគ្រប់គ្រងកិច្ចដំណើរការនៃវិចារណកម្ម/ សនិទានកម្មស្ថាប័ន ជាដើម។ ចំពោះកម្មវិធីកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរំលេចច្បាស់ថា នៅក្នុងបុព្វហេតុនៃការលើកតម្កើងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការផ្ដល់សេវាសាធារណៈរួមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន, ការកែទម្រង់សម្រេចបានសមិទ្ធផលគួរជាទីកត់សម្គាល់ ជាអាទិ៍

*ចំណាយកាន់តែមានលទ្ធភាពទូលំទូលាយជាងមុនទ្វេដង ជាមួយនឹងការគោរពវិន័យ និងធានាប្រសិទ្ធភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ពិសេសជួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកាន់តែចំគោលដៅអាទិភាពឆ្លើយតបបានទាន់សភាពការណ៍ចំពោះមុខ និងទាន់តម្រូវការចាំបាច់ដូចជាការគាំទ្រដល់ការកែទម្រង់តាមវិស័យអាទិភាពនានាជាដើម។*

ការរៀបចំក្របខណ្ឌច្បាប់ និងបទដ្ឋានអនុវត្តយន្តការស្ថាប័ន និងការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ កិច្ចដំណើរការជាប្រក្រតីនៃការបោះឆ្នោតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចដំណើរការនៃការផ្ទេរ និងប្រតិភូកម្មមុខងារពីរដ្ឋបាលថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការបង្កើនសិទ្ធិអំណាច និងការទទួលខុសត្រូវ ក្នុងវដ្តថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការហិរញ្ញវត្ថុ នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាដើម។

ចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកឧត្តម **ម៉ី ទេវស្រុខា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចង្អុលបង្ហាញថាដើម្បីសម្រេចបានប្រព័ន្ធថវិកាមួយ ដែលមានបូរណភាពពេញលេញនៃការគោរពវិន័យថវិកា ស័ក្តិសិទ្ធភាពនៃការវិភាជថវិកា ព្រមទាំងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការកែទម្រង់សម្រេចបានពេញលេញនូវភាពជឿទុកចិត្តបាននៃថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ព្រមទាំងកំពុងផ្សារភ្ជាប់កាន់តែជិតស្និទ្ធរវាងថវិកា និងគោលនយោបាយ ពោលគឺកំណើនសេដ្ឋកិច្ចរក្សាបានជុំវិញ ៧%/ ឆ្នាំ អតិផរណាទាបអាចគ្រប់គ្រងបានជុំវិញ ៣,៥%/ ឆ្នាំ មូលដ្ឋានចំណូលកាន់តែទូលាយ និងគ្រប់គ្រាន់ កាន់តែមានប្រសិទ្ធភាព រីឯចំណាយកាន់តែមានលទ្ធភាពទូលំទូលាយជាងមុនទ្វេដង ជាមួយនឹងការគោរពវិន័យ និងធានាប្រសិទ្ធភាពហិរញ្ញវត្ថុកាន់តែរឹងមាំ ពិសេសជួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល កាន់តែចំគោលដៅអាទិភាពឆ្លើយតបបានទាន់សភាពការណ៍ចំពោះមុខ និងទាន់តម្រូវការចាំបាច់ ដូចជាការគាំទ្រដល់ការកែទម្រង់តាមវិស័យអាទិភាពនានាជាដើម។ ចំពោះកម្មវិធីកែទម្រង់ប្រព័ន្ធច្បាប់ និងវិស័យយុត្តិធម៌ ឯកឧត្តម **ជិន ម៉ាលីន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានគូសបញ្ជាក់ថា នៅក្នុងបុព្វហេតុនៃការពង្រឹងនីតិរដ្ឋ និងការធានាយុត្តិធម៌សង្គម, ការកែទម្រង់សម្រេចបានសមិទ្ធផលយ៉ាងច្រើន ជាអាទិ៍ ការធ្វើទំនើបកម្មប្រព័ន្ធខ្សែសំខាន់ៗដែលជាសសរស្តម្ភនៃនីតិរដ្ឋ ការពង្រឹងរចនាសម្ព័ន្ធស្ថាប័ននៃវិស័យយុត្តិធម៌ ការលើកកម្ពស់ការយល់ដឹង និងការគោរពច្បាប់ ទាំងក្នុងកម្រិតក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ព្រមទាំងការផ្ដល់សេវាយុត្តិធម៌ ទាំងក្នុង និងក្រៅប្រព័ន្ធតុលាការដល់ប្រជាពលរដ្ឋ ឱ្យកាន់តែកៀកកិតជិតស្និទ្ធ និងកាន់តែមានប្រសិទ្ធភាព តម្លាភាពនៅនឹងមូលដ្ឋាន ពិសេស ពលរដ្ឋងាយរងគ្រោះ។

ជាស្មារតីរួម ការដ្ឋានកែទម្រង់ទាំង៤ខាងលើ បានបង្ហាញព្រមគ្នា នូវទស្សនវិស័យ តទៅអនាគត ប្រកបដោយគោលបំណងដ៏មហិច្ឆិតា ដោយផ្សារភ្ជាប់ជាមួយនឹងលទ្ធភាពប្រាកដនិយមជាក់ស្តែង ឆន្ទៈនយោបាយមោះមុតឥតរាថយ សមត្ថភាពមនុស្ស និងស្ថាប័ន ស្មារតីនៃភាពជាម្ចាស់ការទទួលខុសត្រូវខ្ពស់ សម្បជញ្ញៈនៃភាពបន្ទាន់ និងស្មារតីតម្រង់ឱ្យចំគោលដៅអាទិភាពនៃការកែទម្រង់ ក្នុងបុព្វហេតុរួមនៃវឌ្ឍនភាពសង្គម និងសុខុមាលពលរដ្ឋ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

ចក្ខុវិស័យដឹកនាំការកែទម្រង់ទាំងនេះមានសេចក្តីត្រូវការចាំបាច់ឱ្យលើកកម្ពស់ព្រមៗគ្នា ទាំងក្នុងក្របខណ្ឌផ្ទៃក្នុងរបស់ការដ្ឋានកែទម្រង់នីមួយៗ ទាំងក្នុងក្របខណ្ឌទំនាក់ទំនងជាអន្តរការដ្ឋានកែទម្រង់ពីមួយទៅមួយ ដូចការគូសបញ្ជាក់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីព្រឹកមិញ នៅក្នុងសុន្ទរកថាបើកសិក្ខាសាលា។

***សម្តេចក្រឡាហោម ស ខេង*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*ឯកឧត្តម លោកជំទាវ គណៈអធិបតីជាទីគោរពដ៏ខ្ពង់ខ្ពស់*

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ថ្នាក់ដឹកនាំ និងសមាជិក សមាជិកា*



*សហភាពសហព័ន្ធយុវជនកម្ពុជា និងបងប្អូនយុវជនជាទីគោរពរាប់អានដ៏ជ្រាលជ្រៅ!*

**ទី២) ទត្ថរសៀល**

បានផ្តល់កាលានុវត្តភាពដ៏វិសេសដល់សិក្ខាកាមជាយុវជនទាំងឡាយលើកឡើងយ៉ាងសកម្ម និងអន្តរសកម្មនូវចម្ងល់ តម្រូវការបញ្ជាក់បន្ថែម រួមទាំងបំណងប្រាថ្នា និងការរំពឹងទុកនានារបស់ខ្លួនមកលើការងារកែទម្រង់នីមួយៗ ដាច់ដោយឡែកផង និងជាពិសេសមកលើទំនាក់ទំនងជាអន្តរសកម្ម រវាងការកែទម្រង់មួយទៅកាន់ការកែទម្រង់មួយទៀតផង។



ក្នុងន័យនេះ ទំនាក់ទំនងជាអន្តរការដ្ឋានកែទម្រង់ បានផុសចេញពីខ្លឹមសារនៃកិច្ចពិភាក្សា សំណួរ-ចម្លើយ តាមរយៈទស្សនៈ និងការយល់ឃើញអំពីអន្តរសកម្មចំនួន ៣ ប្រភេទ យ៉ាងតិចដូចខាងក្រោម÷

១. ពិពិធភាពនៃតំណភ្ជាប់ការកែទម្រង់នានា÷ សិក្ខាសាលានេះ បានប្រែក្លាយទៅជាវេទិកានៃការរៀនសូត្រដកស្រង់បទពិសោធពីគ្នាទៅវិញទៅមក ប្រកបដោយភាពសម្បូរបែប និងខុសប្លែកៗពីគ្នា រវាងយុវជន និងអ្នកកែទម្រង់ ក៏ដូចជារវាងអ្នកកែទម្រង់ក្នុងការដ្ឋានទាំងបួនដោយបានទម្លុះរនាំងគំនិតទម្លាយរបាំងវិជ្ជានៃការកែទម្រង់ នៅតាមការដ្ឋាននីមួយៗ ធ្វើឱ្យស្តែងចេញនូវលំហូរមេរៀន និងបទពិសោធជាច្រើន ទាំងជោគជ័យ ទាំងការប្រឈមនានាដែលមិនទាន់ទទួលបានជោគជ័យដែលក្នុងនោះមានបញ្ហាជាមូលដ្ឋានជាច្រើនមានលក្ខណៈប្រហាក់ប្រហែលគ្នា ជាអាទិ៍ ភាពជាអ្នកដឹកនាំ ឆន្ទៈដឹកនាំ ស្មារតីនៃភាពជាម្ចាស់ សមត្ថភាពមនុស្ស និងរចនាសម្ព័ន្ធស្ថាប័ន កិច្ចសម្របសម្រួលស្ថាប័ន និងអន្តរស្ថាប័ន ជាដើម។ ប្រការនេះ បានផ្តល់ជាចម្ងល់មួយថាតើការកែទម្រង់ គឺជាករណីយកិច្ចធម្មជាតិរបស់អ្នកដឹកនាំ ឬយ៉ាងណា?

២. អន្តរសកម្មភាពនៃការពឹងផ្អែកគ្នាទៅវិញទៅមករវាងការកែទម្រង់នានា÷ នៅក្នុងបរិការណ៍មួយចំនួន ការកែទម្រង់មួយ អាចសម្រេចវឌ្ឍនភាពទៅមុខបាន លុះត្រាតែត្រូវពឹងផ្អែកលើសមិទ្ធផលនៃការកែទម្រង់មួយទៀត ដែលមានទំនាក់ទំនងផ្សារភ្ជាប់គ្នាទៅវិញទៅមកជាប់មិនដាច់ និងឆ្លើយឆ្លងគ្នាទៅវិញទៅមក។ ជាក់ស្តែង ការផ្ទេរមុខងារ ឬប្រតិភូកម្មមុខងារពីរដ្ឋបាលថ្នាក់ជាតិ ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការគិតគូររៀបចំ និងអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងធនធានមនុស្ស និងបញ្ហាធនធានហិរញ្ញវត្ថុភ្ជាប់ទៅជាមួយ។ រីឯការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ អាចចោទជាបញ្ហានៃការរៀបចំជំហាននៃការកែទម្រង់វិមជ្ឈការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចឈានទៅដល់គណនេយ្យភាពសមិទ្ធកម្ម មុនរដ្ឋបាលថ្នាក់ជាតិ នៅក្នុងការកែទម្រង់ប្រព័ន្ធថវិកា។ ម្យ៉ាងទៀត សេវាយុត្តិធម៌ក្នុង ឬក្រៅប្រព័ន្ធតុលាការ អាចសម្រេចទៅបានដោយប្រសិទ្ធភាព លុះត្រាតែការគាំទ្រផ្នែកហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូនទន្ទឹមគ្នានឹងការបង្កើតមុខងារផ្តល់សេវាយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ ឬការពង្រឹងសមត្ថភាពរដ្ឋបាលតុលាការ ក្នុងការទទួលយកនូវសិទ្ធិអំណាច និងការទទួលខុសត្រូវជាអង្គភាពថវិកា។

*ទំនាក់ទំនងជាអន្តរសកម្មនៃការកែទម្រង់នេះ ហាក់ដូចជាបានបង្កើតទៅជាសង្សារវដ្តនៃគុណធម៌ ឬគុណវដ្តដែលគុណបំណាច់នៃការកែទម្រង់មួយ នឹងផ្តល់ជាគុណប្រយោជន៍ដល់ការជំរុញល្បឿននៃការកែទម្រង់មួយទៀត នៅក្នុងរង្វង់នៃការគាំទ្រ និងពឹងផ្អែកគ្នាទៅវិញទៅមក*

៣. អន្តរសកម្មភាពនៃការគាំទ្រឱ្យគ្នាទៅវិញទៅមករវាងការកែទម្រង់នានា÷ នៅក្នុងបរិការណ៍មួយចំនួនទៀត វឌ្ឍនភាពនៃការកែទម្រង់មួយ នឹងផ្តល់ជាកម្លាំងគាំទ្រដល់ការសម្រេចលទ្ធផលនៃការកែទម្រង់មួយទៀត ទោះដោយផ្ទាល់ ឬប្រយោលក្តី។ ជាក់ស្តែង កំណើនចំណូលថវិកាជាតិដែលបានមកពីការកែទម្រង់រដ្ឋបាលសារពើពន្ធ និងការពង្រឹងប្រព័ន្ធប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាទ្រព្យសម្បត្តិដែលតុលាការរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ នឹងផ្តល់លទ្ធភាពដល់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌កាន់តែមានថវិកាគាំទ្រប្រសើរឡើង។ រីឯការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវលើការរៀបចំ និងអនុវត្តថវិកាដល់រដ្ឋបាលតុលាការ ជាមួយនឹងសាមញ្ញកម្មនីតិវិធីហិរញ្ញវត្ថុ និងអនុញ្ញាតឱ្យស្ថាប័នតុលាការមានលទ្ធភាពបម្រើសេវាយុត្តិធម៌កាន់តែមានប្រសិទ្ធភាពឆាប់រហ័សជាងមុន។ ម្យ៉ាងទៀត ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រព័ន្ធមុខងារសាធារណៈ បានផ្តល់ជីវភាពថ្មីដល់មន្ត្រីរាជការក្នុងការចូលរួមចំណែកកាន់តែសកម្ម ក្នុងការងារកែទម្រង់ តាមវិស័យអាទិភាព ដូចជាវិស័យអប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ បរិស្ថានជាដើម។

អាស្រ័យហេតុនេះ ទំនាក់ទំនងជាអន្តរសកម្ម នៃការកែទម្រង់នេះ ហាក់ដូចជាបានបង្កើតទៅជាសង្សារវដ្តនៃគុណធម៌ ឬគុណវដ្ត (Virtuous Circle) ដែលគុណបំណាច់នៃការកែទម្រង់មួយ នឹងផ្តល់ជាគុណប្រយោជន៍ដល់ការជំរុញល្បឿននៃការកែទម្រង់មួយទៀត នៅក្នុងរង្វង់នៃការគាំទ្រ និងពឹងផ្អែកគ្នាទៅវិញទៅមក ទន្ទឹមនឹងនេះ ក៏ហាក់ដូចជាបានត្រួសត្រាយមាគ៌ាដោះស្រាយការប្រឈម ឆ្ពោះទៅរកនិន្នាការនៃការផ្សារភ្ជាប់ទំនាក់ទំនងនៃការកែទម្រង់ផ្សេងៗគ្នាឱ្យកាន់តែជិតស្និទ្ធ នៅលើមាគ៌ាដឹកនាំពីអន្តរការដ្ឋាននៃការកែទម្រង់ ទៅកាន់ការដ្ឋានអន្តរកែទម្រង់។

នៅក្នុងមនោសញ្ចេតនាទន្ទឹងរង់ចាំត្រងត្រាប់នូវឱវាទានុសាសន៍កែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ពោរពេញដោយភាពជាអ្នកដឹកនាំឆ្នើមវិសេស និងចក្ខុវិស័យវាងវៃវែងឆ្ងាយ ព្រមជាមួយនឹងសព្ទសាធុការពរជ័យ សិរីសួស្តី បវរប្រសើរថ្លៃថ្លា ខ្ញុំបាទសូមគោរពអញ្ជើញ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សូមលោកមេត្តាឡើងថ្លែងសុន្ទរកថាបិទអង្គសិក្ខាសាលាស្តីពី "**បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា**" ដោយក្តីសណ្តោស៕■

## អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
## ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### គណៈគ្រប់គ្រង ÷

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វិណែល | អគ្គលេខាធិការរង **អ.គ.ហ.** |

### រៀបចំអត្ថបទដោយ ÷

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| រិទ្ធី សត្រា | មន្ត្រីជំនាញ |

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| លី ពង្សរតនា | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | ជំនួយការ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | ជំនួយការ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញ |
| ផេង សុខម៉ៃ | ជំនួយការ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីថវិកា |
| លឿង សុវណ្ណឌី | ជំនួយការមន្ត្រីថវិកា |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ÷

ក្រុមការងារកែទម្រង់នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគោលនយោបាយ

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សូ សុខប៊ុនធឿន មន្ត្រីជំនាញជាន់ខ្ពស់វិស័យសាធារណៈ នៃធនាគារពិភពលោក

### នវានុវត្ត និងកែសម្រួលដោយ ÷

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| ឈុន ម៉ារឌី | មន្ត្រីជំនាញ |
| លី ពង្សរតនា | មន្ត្រីជំនាញ |

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm